Formation, Dialogue, Cooperation

# អ្នកនាំសារ
# The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី៨ ថ្ងៃទី០១-៣១ ខែសីហា ឆ្នាំ២០១៥ លក់តម្លៃ ១០០០រៀល

លេខ ៨៩

## ដោះស្រាយបញ្ហាព្រំដែន តាមផ្លូវឯកភាពផ្ទៃក្នុង




អេម៉ាណូអែល
"សម្លេងផ្សាយពីព្រះសហគមន៍កាតូលិក"

| | | |
|---|---|---|
| ភ្នំពេញ | : | **FM 104 Mhz** ម៉ោង ៥:០០- ៦:០០ រសៀល |
| បាត់ដំបង | : | **FM 91.0 Mhz** ម៉ោង ៧:៣០- ៨:៣០ យប់ |
| សៀមរាប | : | **FM 107.5 Mhz** ម៉ោង ៧:០០- ៨:០០ យប់ |
| កំពង់ធំ | : | **FM 103.5 Mhz** ម៉ោង ៧:០០- ៨:០០ យប់ |
| កំពង់ចាម | : | **FM 100.5 Mhz** ម៉ោង ៧:០០- ៨:០០ យប់ |
| ព្រះសីហនុ | : | **FM 92.5 Mhz** ម៉ោង ៥:០០- ៦:០០ រសៀល |
| កំពត | : | **FM 93.25 Mhz** ម៉ោង ៥:០០- ៦:០០ រសៀល |

កម្មវិធីវិទ្យុសម្រាប់យុវជន
ខ្ញុំត្រូវការអ្នក
ផ្សាយតាមរលកធាតុអាកាស
FM 99.5Mhz រាល់ថ្ងៃអង្គារ៍
វេលាម៉ោង ១០:០០-១១:០០ព្រឹក

# រូបថតសកម្មភាពទិវាយុវជនឡាវ កម្ពុជា











CSC
Formation, Dialogue, Cooperation

ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ

Tel/Fax : (855) 23 224 120

Email : csccambodia@gmail.com / Website : www.catholiccambodia.org

ចាងហ្វាង : លោក លី សុវណ្ណា

សេចក្តីប្រកាសលេខ: ១០១ ព.ម.ប្រ.ក/ ០៥-កុម្ភៈ-២០១៤

# បញ្ហាព្រំដែន កម្ពុជា វៀតណាមជាចំណុចដ៏រសើបបំផុតនៅកម្ពុជា



*លោក លី សុវណ្ណា*
*ចាងហ្វាងកាសែតអ្នកនាំសារ*

ប៉ុន្មានខែចុងក្រោយនេះ បញ្ហាព្រំដែនកម្ពុជា និងវៀតណាម បានចាប់កក្រើកឡើងវិញ តាំងពីពេលដែលពលរដ្ឋតាមបណ្តោយព្រំដែន ត្រូវអផ្សាធរវៀតណាម បាញ់ថ្នាំកំទេចដំណាំរបស់គេ។ ក្រោយព្រឹត្តិការណ៍នេះ មន្ត្រីទទួលកិច្ចការអន្តរជាតិ ក៏ដូចជាមន្ត្រីទទួបន្ទុកកិច្ចការព្រំដែន បានដាក់បន្ទុកលើពលរដ្ឋកម្ពុជាថា បានធ្វើចំការលើដីរបស់វៀតណាម។ ព្រឹត្តិការណ៍ក្រោយៗទៀត ក៏កើតមានតាមបន្ទាត់ព្រំដែន ជាមួយវៀតណាម រហូតដល់កម្ពុជាបានចេញកំណត់ទូត ឲ្យវៀតណាម បញ្ឈប់រាល់សកម្មភាពនានាតាមព្រំដែន ប៉ុន្តែស្ថានភាព មិនបានធូរស្រាលឡើយ។ អំពើហិង្សាបានកើតឡើង រវាងពលរដ្ឋវៀតណាម និង អ្នកដែលតាំងខ្លួនជា "អ្នកស្នេហាជាតិ" ចុះទៅពិនិត្យបង្គោលព្រំដែននៅក្នុងខេត្តស្វាយរៀង។

ក្រោយព្រឹត្តិការណ៍ហិង្សានេះ នាំឲ្យគណៈកម្មការ ទទួលបន្ទុកកិច្ចការព្រំដែនប្រទេសទាំងពីរ ជួបគ្នាបន្ទាន់នៅភ្នំពេញ ដើម្បីបន្ធូរស្ថានការដ៏តានតឹងនេះ ហើយបន្តដំណើរបោះបង្គោលព្រំដែនរវាងប្រទេសទាំងពីរ ដោយសន្តិភាព។

ទោះជាយ៉ាងនេះក្តី តំណាងរាស្ត្របក្សប្រឆាំងបានចោទរដ្ឋាភិបាល ដែលដឹកនាំ ដោយគណបក្សប្រជាជន ថាគ្មានឆន្ទៈ គឺចោទរដ្ឋាភិបាលថា បានធ្វើឲ្យបាត់ដី និងទាមទារឲ្យរដ្ឋាភិបាលបង្ហាញភស្តុតាងនានា ដែលធានាថាវៀតណាម គោរពអធិបតេយ្យភាពទឹកដីរបស់កម្ពុជា។ ពួកគេចោទ ហ៊ានរហូតប្រើពាក្យថា គណបក្សប្រជាជន ជាអាយ៉ងរបស់វៀតណាម ទៀតផង។ រដ្ឋាភិបាល ក៏បានច្រានចោលជាច្រើនលើកច្រើនសារ ចំពោះការចោទប្រកាន់ទាំងអស់នេះ។ ប្រមុខរដ្ឋាភិបាល ក៏ធ្លាប់បានបកស្រាយរយៈពេលជាង ៥ម៉ោង នៅក្នុងសភា អំពីការដោះស្រាយបញ្ហាព្រំដែនជាមួយវៀតណាមនេះ ដោយធានាថា មិនបានធ្វើឲ្យកម្ពុជាបាត់ដីទៅវៀតណាមនោះឡើយ។

តាមពិតទៅ ព័ត៌មាននានា ទាក់ទងទៅនឹងការដោះបញ្ហាព្រំដែននេះ មិនត្រូវបានផ្សព្វផ្សាយឲ្យបានទូលំទូលាយនោះឡើយ ជាហេតុបណ្តាលឲ្យការចោទប្រកាន់បន្តរហូតមក។ ការលាក់ព័ត៌មាននេះ មិនគ្រាន់តែជាមួយពលរដ្ឋទូទៅទេ សូម្បីមន្ត្រីក្នុងជួររដ្ឋាភិបាល ក៏មិនបានយល់ច្បាស់ នូវព័ត៌មានទាំងនោះមានដូចជា ចៅហ្វាយខេត្តមួយចំនួនតាមបន្ទាត់ព្រំដែនវៀតណាម។ ពួកគេបានចោទគណៈកម្មការ ទទួលបន្ទុកកិច្ចការព្រំដែនថា មិនបានបញ្ជាក់ច្បាស់លាស់ អំពីដីកម្ពុជានៅកន្លែងពិតប្រាកដនោះទេ។ ការចោទប្រកាន់នេះ បានកើតឡើង ក្នុងពេលសន្និបាតផ្សព្វផ្សាយព័ត៌មាន អំពីព្រំដែននៅក្រសួងមហាផ្ទៃ។

ជាការពិតណាស់ ព័ត៌មានទាំងអស់នេះ មិនមែនចេះបង្ហាញចេញងាយៗនោះឡើយ ព្រោះវាប៉ះពាល់សន្តិសុខជាតិ។ តែក៏មិនគួរលាក់ពេកដែរ។

ការចោទប្រកាន់ ការខ្វែងគំនិតគ្នារឿងផែនទី ដែលយកទៅធ្វើការជាមួយវៀតណាម គឺនៅមានមិនចេះចប់ ហើយម្នាក់ៗបានយកត្រូវរៀងៗខ្លួន ខាងរដ្ឋាភិបាល ក៏មានអំណះអំណាងច្បាស់លាស់ តែតំណាងរាស្ត្រខាងបក្សប្រឆាំងថា ផែនទីមិនត្រឹមត្រូវ នាំឲ្យបាត់ដីព្រោះពួកគេផ្អែកលើផែនទី ដែលបានទិញពីផ្សារ នៅស្រុកបារាំងមកផ្ទៀងផ្ទាត់ និងការជួបផ្ទាល់ជាមួយពលរដ្ឋដែលរស់នៅតាមបន្ទាត់ព្រំដែន។ កត្តានេះ បានជំរុញប្រមុខរាជរដ្ឋាភិបាលថ្មីៗនេះ ស្នើសុំផែនទី ពីអង្គការសហប្រជាជាតិ ដែលកម្ពុជាតម្កល់នៅទីនោះ ពីសហរដ្ឋអាមេរិក ពីអង់គ្លេស និងពីបារាំងព្រោះបារាំង ធ្លាប់ជាអាណាព្យាបាលរបស់កម្ពុជា ដើម្បីយកមកផ្ទៀងផ្ទាត់ជាមួយផែនទី ដែលកម្ពុជា កំពុងប្រើបោះបង្គោលជាមួយវៀតណាម។ ការខ្វែងគំនិតគ្នានេះ ក៏បានរុញឲ្យកំដៅនយោបាយកើនកំដៅឡើងវិញដែរ។

សរុបមក បញ្ហានេះជារឿងដ៏ស្មុគស្មាញ ត្រូវការពេលវេលាយូរ មិនងាយចប់ឆាប់ៗនោះឡើយ ក្នុងនាមជាពលរដ្ឋមួយរូប សូមអំពាវនាវ ដល់ពលរដ្ឋកម្ពុជាទាំងអស់ថា ពេលនេះជាពេលដែលយើង ត្រូវខិតខំស្វែងរកចំណុចឯកភាពគ្នាផ្ទៃក្នុងកម្ពុជា ដើម្បីអាចតតាំងជាមួយប្រទេសជិតខាងបាន។ បើផ្ទៃក្នុងរង្គោះរង្គើរ យើងគ្មានកម្លាំងគ្រប់គ្រាន់ឡើយ។ យើងមានជំនឿលើរាជរដ្ឋាភិបាល ក្នុងការដោះស្រាយបញ្ហាទាំងនេះយើងសង្ឃឹមថា កម្ពុជានឹងមូលគំនិតគ្នាតែមួយ ដើម្បីដោះស្រាយជាតិទាំងមូល ហើយផែនទីដែលទទួលពីអង្គការសហប្រជាជាតិ និង ប្រទេសមហាអំណាច នឹងជួយឲ្យយើងយល់កាន់ច្បាស់ ពីទឹកដីកម្ពុជាយ៉ាងច្បាស់លាស់។ គ្មាននរណាម្នាក់ ធ្វើនយោបាយ មិនស្រឡាញ់ជាតិរបស់ខ្លួនឡើយ។ ប្រវត្តិសាស្ត្រ នឹងចារឈ្មោះវីរកម្ពុជាទាំងអស់នាពេលអនាគត៕




# អ្នកទីក្រុងចាប់ផ្តើមព្រួយបារម្ភខ្លាំងអំពីផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុ



*គោកំពុងស៊ីសំណាបដែលក្រៀមស្វិតដុះនៅតាមស្រែដែលគ្មានទឹកនៅក្នុងខេត្តកំពង់ស្ពឺ (កក្កដា ២០១៥ )។ រូបថតៈ កញ្ញា*

## អ្នកជំនាញ ៖ កម្ពុជាមិនរាំងស្ងួតទេ

លោក ចាន់ យុត្ថា អ្នកនាំពាក្យក្រសួងធនធានទឹក និង ឧតុនិយមបានមានប្រសាសន៍ថា កុំបារម្ភឆ្នាំនេះកម្ពុជាមិនជួបគ្រោះរាំងស្ងួតទេ ។

លោកមានប្រសាសន៍ថា កម្ពុជាមិនស្ថិតនៅក្នុងបាតុភូតនេះទេ ។

លោកបញ្ជាក់ថា "កម្ពុជាមិនគួរបារម្ភដូចជាថៃ និងឡាវអីទេ ដោយសារយើងស្ថិតនៅអន្តរកាល នៃបាតុ-ភូត អែលនីណូ និងឡានីណា"។

លោកបានបន្តថា នៅចន្លោះពីខែសីហា ដល់ខែកញ្ញា របាយទឹកភ្លៀងនឹងចាប់ផ្តើម រាយប៉ាយពេញប្រទេសឡើងវិញ ។

លោកបានបន្តទៀតថា ចំពោះបញ្ហាគ្រោះធម្មជាតិផ្សេងៗទៀត ដូចជាទឹកជំនន់ គឺអាចមិនមានធ្ងន់ធ្ងរហើយព្យុះវិញ ក៏មិនជាច្រើនដែរ ដោយមកដល់ ពេលនេះ កម្ពុជាបានគេចផុតពីព្យុះចំនួន១២ហើយ ។

លោកបានបន្តទៀតថា ជាមធ្យមកម្ពុជាក្នុងមួយឆ្នាំ គឺអាចទទួលឥទ្ធិពលនៃព្យុះប្រមាណជា៥ នៅក្នុងចំណោមព្យុះប្រមាណជា ២៥ ទៅ២៧ ដែលកើតមាននៅមហាសមុទ្រ ប៉ាស៊ីហ្វិក និងនៅសមុទ្រចិនខាងត្បូង ។

ក្រៅពីបញ្ហានយោបាយ ដ៏ក្តៅគគុកជុំវិញរឿងព្រំដែន និងរឿងចាប់សកម្ម-ជនគណបក្សសង្គ្រោះជាតិ ១១ នាក់កាត់ទោស ដោយសារតែរឿង កុប្បកម្មនៅទីលានប្រជាធិបតេយ្យ កាលពីខែកក្កដា ឆ្នាំ២០១៤ នៅពេលនេះ ប្រធានបទក្តៅ ដែលពលរដ្ឋកំពុងតែយកចិត្តទុកដាក់ផងដែរនោះ គឺគ្រោះរាំងស្ងួត ។

ប្រជាពលរដ្ឋ នៅក្នុងទីក្រុងភ្នំពេញ ដែលជាទូទៅ ច្រើនតែជាអ្នកដែលអាស្រ័យផលពីផលិតផលផ្សេងៗ ជាពិសេស គឺកសិកម្ម សម្រាប់បម្រើជីវភាពរបស់ពួកគេ នៅពេលនេះចាប់ផ្តើមបង្ហាញនូវក្តីព្រួយបារម្ភអំពីបម្រែបម្រួលអាកាសធាតុនេះហើយ។

លោក ណៃ សម្បត្តិ ជាមន្ត្រីរាជការមួយរូប បានមានប្រសាសន៍ នៅក្នុងពេលជួបជុំស្រស់ស្រូបអាហារពេលព្រឹកនៅអាហារដ្ឋានមួយ នៅតាមដងផ្លូវ ២៧១ បានឲ្យដឹងថា ការព្រួយបារម្ភអំពីគ្រោះរាំងស្ងួត គឺនៅទូទាំងតំបន់តែម្តងឆ្នាំនេះ។

លោក សម្បត្តិ បានឲ្យដឹងថា លោកបានតាមដានព័ត៌មានអន្តរជាតិ គេថាប្រទេសជាច្រើននៅអាស៊ីអគ្នេយ៍ នឹងរងគ្រោះដោយសារ តែអាកាសធាតុរាំងស្ងួត ដូចនៅប្រទេសថៃ ខេត្តច្រើនណាស់កំពុងតែរាំងស្ងួត ជាពិសេសខេត្តដែលធ្វើស្រែសំខាន់ៗ ដោយឡែកនៅកម្ពុជា ហាក់មិនទាន់មានព័ត៌មានរាយការណ៍ទេ ប៉ុន្តែប្រហែលជាជៀសមិនរួចនឹងឥទ្ធិពលនៃគ្រោះរាំងស្ងួតទេ ដោយសារតែពេលនេះ ដល់រដូវវស្សាទៅហើយ តែភ្លៀងធ្លាក់ទើបតែបាន ២ទៅ៣ដងតែប៉ុណ្ណោះ ។

លោក សម្បត្តិ ដែលមានស្រុកកំណើត នៅក្នុងស្រុកគីរីវង្ស ខេត្តតាកែវ បានបញ្ជាក់ថា "នៅភ្នំពេញយើងគ្រាន់បើ គឺមានភ្លៀងធ្លាក់២ ទៅ៣ដងដែរ តែបងប្អូនខ្ញុំ នៅឯស្រុកកំណើតមកនិយាយថា ដីហុយទ្រលោម រកតែភ្លៀងមួយដំណក់គ្មាន"។

អង្គុយនៅក្បែរនឹងលោក សម្បត្តិ អ្នកជំនួញខ្នាតតូចមួយរូប ដែលបានប្រាប់ឈ្មោះថា សាំង សុខចំរើន បានឲ្យដឹងថា មនុស្សជាច្រើន និយាយអំពីបញ្ហានេះ រួមទាំងកម្មករ នៅក្នុងរោងសិប្បកម្មរបស់លោក ។

លោកបានបញ្ជាក់ថា "កម្មករខ្ញុំពួកគេនិយាយថា ស្រុកពួកគេអត់មានភ្លៀងទេ ហើយឪពុកម្តាយពួកគេ កំពុងតែព្រួយបារម្ភរឿងអត់អង្ករ"។

កម្មករ ដែលកំពុងតែបម្រើការនៅ រោងសិប្បកម្មរបស់លោក ចំរើន គឺមកពី ខេត្តផ្សេងៗ ដូចជា កំពង់ធំ និង តាកែវ ។ល។

លោកបានដឹងអំពីបញ្ហានេះ ដោយសារតែអ្នកខ្លះ ច្រើនឲ្យឪពុកម្តាយរបស់ពួកគេផ្ញើអង្ករពីស្រុកមកពួកគេ ប៉ុន្តែខែនេះ អ្នកខ្លះសុំលោកបើកប្រាក់ខែមុនដើម្បីទិញអង្ករ។ នៅម្តុំផ្សារ នៅអាហារដ្ឋានមួយកន្លែងទៀតម្តុំអូឡាពិក ដែលបណ្តាអាជីវករ តែងតែមកជួបជុំគ្នាដើម្បីទទួលទានអាហារពេលព្រឹក ក៏មានការពិភាក្សា អំពីគ្រោះរាំងស្ងួតនេះផងដែរ ។

លោក ឈៀក គឹមហ៊ុយ បានឲ្យដឹងថា ឆ្នាំនេះតម្លៃអង្ករ បន្លែ ផ្លែឈើនិយាយរួម គឺស្បៀងអាហារ ប្រហែលជាឡើងថ្លៃ ដោយសារតែគ្រោះរាំងស្ងួត ដូច្នេះ សេដ្ឋកិច្ចរបស់ប្រទេស ក៏ប្រហែលជា អាចមានផលប៉ះពាល់ខ្លះ ហើយទោះតិចទោះច្រើន។

លោកបានបញ្ជាក់ថា "តែអ្នកស្រែធ្វើស្រូវមិនបាននោះ អ្នកលក់មាសនៅផ្សារ កុំសង្ឃឹមថាលក់ដាច់ឲ្យសោះ"។

លោកបានបន្តថា នៅស្រុកយើងនៅពេលនេះ ហាក់មិនទាន់មានព័ត៌មានធំដុំទេ តែនៅថៃ លោកបានមើលព័ត៌មានឃើញថា គ្រោះរាំងស្ងួតគឺកើតមាននៅរាប់ខេត្ត ប៉ុន្តែបើនៅស្រុកយើងកើតបែបនោះមែនប្រាកដជាវិវរមិនខាន ។

លោកបានបញ្ជាក់ថា "ស្រុកគេ គេមានបច្ចេកទេស ធ្វើភ្លៀងសិប្បនិម្មិតបាន ប៉ុន្តែបើនៅស្រុកយើង ជួបស្ថានការណ៍បែបនេះប្រាកដជាយ៉ាប់"។

លោក តែ សុកលៀង ជាអាជីវករមួយរូបដែរនោះ បានបន្តថា ជាការពិតគ្រោះធម្មជាតិ មិនមែនសម្លាប់តែអ្នកស្រែទេ គឺទាំងអស់គ្នា។ លោកបានបញ្ជាក់ថា "អ្នកស្រែអត់បាយនរណាក៏អត់បាយដែរ ដូច្នេះទាំងអស់គ្នាចូរប្រ-យ័ត្ន និងពិសេសអ្នកនយោបាយ"។

លោក បានបន្តថា ស្រុកទេសត្រូវរ៉ូវគ្នា មិនបានប៉ុន្មានផង ប៉ុន្តែឥឡូវចាប់ផ្តើមតឹងសរសៃករដាក់គ្នាទៀតហើយ ។

លោកបានបន្តទៀតថា នៅពេលនេះនៅមិនទាន់ដល់ពេល បោះឆ្នោតផងអ្នកនយោបាយមិនគួរ មកលេងល្បែងនេះទេ វាជាតំណាក់កាល នៃការរួបរួមគ្នាដោះស្រាយបញ្ហានឹងគ្នា ប៉ុន្តែនៅសុខៗ ក៏ទៅយកបញ្ហាព្រំដែន បញ្ហាអំពើហិង្សា កាលពីឆ្នាំមុនមកលេងឯណាទៅវិញ ឯអារឿងជាតិ រឿងសេដ្ឋកិច្ច រឿងសុខទុក្ខស្លាប់រស់របស់រាស្ត្រអត់គិត។

លោកបានបញ្ជាក់ថា "ខ្ញុំឆ្ងល់ដែរអ្នកនយោបាយតែទាំងពីរទាំងបី គណ-បក្សនេះ ហេតុអ្វីក៏មិនគិតធ្វើអ្វីដែលវាចំណេញដល់ជាតិ ដូចជារឿង ធ្វើម៉េចឲ្យកសិករមានទឹកធ្វើស្រែ ខួបប្រាំងខួបវស្សាដូចគេមិនគិត ទៅគិតតែបញ្ហាដែលនាំស្រុកនាំទេសក្តៅក្រហាយ"។

*ដោយអរិយបុត្រ*



# យុវជនប្រាប់យុវជនឲ្យរិះគិតអំពីមុខរបរនិងរៀនធ្វើការរកប្រាក់

រឿងដែលយុវជនកម្ពុជា មិនទម្លាប់ស្វែងរកការងារធ្វើ ដើម្បីរកទុនទៅបន្តការសិក្សា វាមិនមែនជារឿងថ្មីសម្រាប់សង្គមកម្ពុជា ប៉ុន្តែស្ថានភាពបច្ចុប្បន្ននេះក៏មានយុវជនមួយចំនួន បានអនុវត្តការរៀនបណ្ដើររកការងារធ្វើបណ្ដើរមិនជាតិចនោះទេមកដល់បច្ចុប្បន្ននេះ។

លោក ខេង សុភក្រ ជាយុវជនមួយរូបដែលបានអះអាងថា ជាអ្នកដើរលក់ផលិតផលនំ និង កាហ្វេរបានអះអាងថា នៅពេលនេះ គំនិតទារលុយឪពុកម្ដាយដើម្បីយកលុយទៅរៀន លែងនៅក្នុងផ្នត់គំនិតរបស់លោកហើយ ។

សុភក្រ ដែលបច្ចុប្បន្នកំពុងតែរៀនឆ្នាំទី ២ ផ្នែកទីផ្សារ បានអះអាងថា សព្វថ្ងៃនេះប្អូន អាចរៀនរកប្រាក់ពីខ្លួនឯងបាននៅក្នុងមួយខែ ពី៨០ ដុល្លារ ទៅ ២៥០ដុល្លារ នៅក្នុងមួយខែ ដែលអាចឲ្យប្អូន ល្មមនឹងចាយវាយគ្រប់គ្រាន់ និងសន្សំខ្លះសម្រាប់ជួយបង់ថ្លៃសាលា ។

សុភក្រ បានបញ្ជាក់ថា "ខ្ញុំចាប់ផ្ដើមបែកគំនិតរៀនផងធ្វើការសន្សំលុយផងនេះតាំងពីចុងឆ្នាំទី១"។

សុភក្រ បានឲ្យដឹងថា មូលហេតុដែលប្អូនបែកគំនិត ស្វែងរកការងារធ្វើនេះ គឺដំបូងឡើយ គឺប្អូនបានទៅចូលរួមពិធីតាំងពិពណ៌ការងារ ហើយនៅពេលនោះ មានវាគ្មិនជាយុវជនល្អៗ និងមានសមត្ថភាពលើកទឹកចិត្ត ហើយក្រោយមក ប្អូនក៏បានទៅដាក់ពាក្យធ្វើការនៅកន្លែងលក់អាហារមួយកន្លែង នៅផ្ដុំសាលាសន្ធរមុខ ដោយបានប្រាក់ខែ៨០ ដុល្លារ ធ្វើការតែត្រឹមពីម៉ោង ៨ ដល់ម៉ោង ៥ និងរៀនយប់ ប៉ុន្តែក្រោយមកដោយសារតែ ការងារនោះវាពេញម៉ោងពិបាកលៃពេលទៅរៀន ក៏បានចេញទៅធ្វើការជាអ្នកទីផ្សារដើរលក់កាហ្វេរ លក់នំវិញ ។

សុភក្រ បានអះអាងថា ដំបូងអាណាព្យាបាលរបស់ប្អូន គឺមិនឲ្យប្អូនធ្វើការទេ ដោយខ្លាចប្អូនរៀនមិនកើត តែឥឡូវគាត់យល់ហើយ ថែមទាំងអាណិតប្អូនទៀត ។

សុភក្របានបញ្ជាក់ថា "ដំបូងប៉ាចង់វៃខ្ញុំ។ គាត់ខឹងថា ខ្លាចគាត់ចិញ្ចឹមមិនរស់បានទៅរកការងារធ្វើ ម៉ាក់វិញក៏ខឹងដែរ ប៉ុន្តែឥឡូវគាត់យល់ ហើយពេលខ្លះគាត់អាណិតខ្ញុំទៀត"។

ក្រៅពីសុភក្រចេញ នៅមានយុវជនកម្ពុជាជាច្រើនទៀតដែលសំរេចចិត្តដូចសុភក្រ ដែលចេញធ្វើការបណ្ដើរសិក្សាបណ្ដើរ នៅក្រោមទស្សនៈ និងគោលគំនិតថ្មីដែលពួកគេនិយាយថា សម័យនេះជាសម័យ ដែលយុវជនគួរតែឈប់លូកដៃសុំលុយពីអាណាព្យាបាល ទៅចាយទៀតហើយ ។

លោក សឹង ភាឫទ្ធ ជានិស្សិតរៀនផ្នែក បច្ចេកវិទ្យាព័ត៌មានមួយរូបបានឲ្យដឹងថា ឪពុកម្ដាយឲ្យលុយ និងចិញ្ចឹមយើងម្នាក់ៗតាំងពីតូចមក អស់លុយច្រើនណាស់ ដូច្នេះបើសិនជាអាច យើងគួររកការងារធ្វើ ជួយសម្រួលគាត់ខ្លះជារឿងដែលប្រសើរបំផុត ។

លោក ភាឫទ្ធ បានបញ្ជាក់ថា "ពេលសុំម៉ែឪចាយស្រួលណាស់ ដល់ខែទៅសុំៗ ប៉ុន្តែដល់ចេញរកខ្លួនឯងបានដឹងថា វាយ៉ាងម៉េច ហើយវាមានន័យយ៉ាងម៉េច ហើយក៏ស្រណុកចិត្តយ៉ាងម៉េចដែរ"។

លោកបានបន្តទៀតថា ដូចជារូបលោកដូច្នេះ ដើម្បីបានប្រាក់៤ ទៅ ១០ ដុល្លារ មិនមែនជារឿងងាយស្រួលទេ គឺត្រូវទៅជួសជុលកុំព្យូទ័រ ធ្វើនេះធ្វើនោះច្រើន ប៉ុន្តែដល់បានមក យើងស្រួលចិត្ត ហើយយើងអាចធ្វើអ្វីបាន ពីព្រោះនោះជាលុយរបស់យើង ។

ភាឫទ្ធ បានបញ្ជាក់ថា "លុយសល់ពីការងារក្រៅម៉ោងសព្វថ្ងៃនេះខ្ញុំ និងមិត្តភ័ក្រ គឺកំពុងតែចូលលុយគ្នា បើកហាងជួសជុល កុំព្យូទ័រមួយកន្លែងហើយឥឡូវ គឺកំពុងតែរកកន្លែងជួលផ្ទះ"។

ជុំវិញបញ្ហាការងារនេះ សុភក្រ បានឲ្យដឹងថា សម័យនេះ សម័យអាស៊ានហើយ យុវជនយើងគួរទម្លាប់រៀនតាមពួកអឺរ៉ុប។

សុភក្របានបញ្ជាក់ថា "នៅក្នុងវីដេអូ ឲ្យតែរៀនចប់វិទ្យាល័យ ឬ កំពុងរៀនមហាវិទ្យាល័យ គេចេញទៅរត់តុ លាងចានរកការងារធ្វើខ្លួនគេ ហើយខ្ញុំក៏ចង់ធ្វើដូចគេ ហើយខ្ញុំក៏មានសមត្ថភាពធ្វើដូចគេ"។

ទន្ទឹមនឹងទស្សនៈថ្មី របស់យុវជនកម្ពុជាសម័យថ្មីនេះ ជាទស្សនៈរបស់អាណាព្យាបាលមួយចំនួន ហាក់មិនគាំទ្រ ហើយអាណាព្យាបាលមួយចំនួនបានសារទរ និងលោកទឹកចិត្តឲ្យយុវជនកម្ពុជាប្រកាន់យកគោលគំនិតនេះ។

មន្ត្រីរាជការមួយរូប ដែលសុំមិនបញ្ចេញឈ្មោះបានឲ្យដឹងថា លោកមិនទាន់ចង់ឲ្យកូនប្រុស កូនស្រីរបស់លោករកការងារធ្វើនៅឡើយទេ ពីព្រោះវាមិនទាន់ដល់ពេល ណាមួយបើសិនជារៀនផងធ្វើការផងវាអាចបែកអារម្មណ៍ ។

លោកបានបន្តថា "ធ្វើការម៉េចកើត បើខ្ញុំឲ្យវារៀនដល់ទៅពីរមហាវិទ្យាល័យ គឺពេលថ្ងៃរៀនគណនេយ្យ ហើយពេលយប់រៀនភាសាអង់គ្លេស"។

លោកបានបន្តថា វ័យត្រឹម ២១ដល់ ២៥ ឆ្នាំរៀនសន្សំចំណេះសិនទៅ ដល់ពេលរៀនចប់ត្រឹមត្រូវ ចាំចេញទៅរកការងារធ្វើទើបវាបានការងារល្អៗធ្វើ ។

លោក ជា ឆេងគីម ជាអាណាព្យាបាល និងជាអាជីវករមួយរូប បានឲ្យដឹងថា លោកមិនមានទស្សនៈអ្វីឲ្យប្រាកដទេ សម្រាប់ពួកកូនៗរបស់លោក ដោយលោក បណ្ដោយតាមការសម្រេចចិត្តរបស់វា ប៉ុន្តែរហូតមកដល់ពេលនេះ ក្នុងចំណោមកូនរបស់លោក៤នាក់ គឺ ២នាក់បានចេញទៅធ្វើការអស់ហើយ ។

លោកបានអះអាងថា "អាធំពីរនាក់ខ្ញុំលែងពិបាកហើយ គឺវាចេះរស់ វាចេះរកលុយចាយខ្លួនវាហើយ តែនៅអាតូចពីរនាក់ទៀត កំពុងរៀនសាលាចិនផងខ្មែរផង"។

លោកបានបញ្ជាក់ថា "ការងារអ្វីបានប្រាក់ប៉ុន្មានខ្ញុំមិនខ្វល់ទេ ឲ្យតែធ្វើការទោះការងារស្មើក៏មិនថោកទាបទេ នេះជាតម្លៃរបស់វា"។ លោកបានបន្តថា "ឲ្យវាចេញធ្វើការ រៀនរករៀនរស់ដោយខ្លួនឯង ទើបដឹងថា ទឹកវាក្ដៅវាត្រជាក់ប៉ុណ្ណា"។

លោកបានអះអាងថា សម្រាប់កូនរបស់លោកធំៗទាំងពីរនេះគឺ អាមួយធ្វើការជាអ្នកបកប្រែឲ្យចិន នៅរោងចក្រ ហើយយប់វារៀនគ្រប់គ្រង អាហ្នឹងឥឡូវចង់បែកគំនិតថា ទៅរកស៊ីវិញ ពេលវារៀនចប់។ លោកបានបន្តថា អាហ្នឹងឆ្លាត ពេលវាទៅចិន ទៅបរទេសជាមួយមេរបស់វាអី មកវិញឃើញវាអង្គុយគិតអង្គុយសរសេរ ពេលដែលលោកសួរវាទៅ គឺថាវាសន្សំបទពិសោធ៍ ទុកបើកក្រុមហ៊ុនខ្លួនវា។ ដោយឡែកអាទីពីរមិនទាន់ដឹងទេ ឃើញទើបតែទៅធ្វើការបានប្រមាណជា៣ខែ ប៉ុន្តែអាហ្នឹងចេះទាំងចិន និងអង់គ្លេស ខ្មែរនៅរៀនមហាវិទ្យាល័យពេលយប់ដែរ៕

*ដោយអរិយបុត្រ*

# អង្គការកាតូលិក រួមនឹងប្រជាសហគមន៍ដាំកូនឈើចំនួន ១០០០ ដើមនៅព្រៃឡង់

អង្គការកាតូលិកមួយ រួមជាមួយប្រជាសហគមន៍គ្រប់គ្រងព្រៃឈើ ក្នុងស្រុកសណ្ដាន់ ខេត្តកំពង់ធំ បានដាំកូនឈើចំនួន មួយពាន់ដើម នៅតំបន់ព្រៃការពារ ក្នុងតំបន់ព្រៃឡង់។ កិច្ចការនេះមានគោលបំណង ដើម្បីជំរុញលើកទឹកចិត្តដល់ប្រជាសហគមន៍ ឲ្យខិតខំការពារព្រៃឈើ ដែលនៅសេសសល់ចុងក្រោយនេះ និងជៀសវាង ការកាប់បំផ្លាញបន្តទៀត។

សកម្មភាពនេះ បានប្រព្រឹត្តទៅកាលពីថ្ងៃទី ២៦ - ២៨ ខែកក្កដា ដែលមានអ្នកចូលរួមដាំប្រមាណជា ៧០នាក់ រួមមានសមាជិកដែលមកពីភ្នំពេញ និងប្រជាសហគមន៍មួយចំនួន គឺបានបោះជំរំស្នាក់នៅ ក្នុងព្រៃរបស់សហគមន៍ចំនួនពីរយប់ ។

លោក បូជាចារ្យ ឌែននីស កាព្រីអែលឡ័ង (កាប៊ី) ប្រធានកម្មវិធីបរិស្ថានីនៃអង្គការ ជេស្វីតសឺវីសកម្ពុជា (JSC) បានមានប្រសាសន៍ថា ៖ នេះមិនមែនជាកលើកទីមួយទេ សម្រាប់ការដាំកូនឈើនៅតំបន់ព្រៃឡង់នេះ ។ លោកថា ព្រៃឡង់ជាព្រៃសំខាន់ចុងក្រោយនៅកម្ពុជា ដែលទទួលរងការកាប់បំផ្លាញ ពីសំណាក់ប្រជាពលរដ្ឋ និងឈ្មួញ។ ព្រៃឡង់មានសារៈសំខាន់ណាស់សម្រាប់ជួយ កុំឲ្យមានបម្រែបម្រួលអាកាសធាតុ ជួយច្រោះទឹកដែលហូរចូលទៅបឹងទន្លេសាប ជាដើម។ ព្រៃឡង់ក៏សំបូរសត្វព្រៃផងដែរ។

លោកកាប៊ីបញ្ជាក់ថា ក្រុមជេស្វីតកម្ពុជាចាប់អារម្មណ៍ និងយកចិត្តទុកដាក់ ចំពោះកិច្ចការបរិស្ថាននេះ តាមសន្ត អ៊ីញ៉ាស ៖ "យើងអាចជួបវត្តមានរបស់ព្រះជាម្ចាស់ នៅក្នុងគ្រប់អ្វីៗទាំងអស់"។ ទោះបីកន្លែងនោះ គ្មានព្រះវិហារក្ដី តែយើងទៅកន្លែងដែលគេត្រូវការ ដែលរងគ្រោះ។ យើងគាំទ្រប្រជាសហគមន៍ លើកទឹកចិត្តគេ ចូលរួមជាមួយពួកគេ ទាំងនេះជារបៀបមួយបញ្ជាក់ថា យើងកំពុងបម្រើព្រះជាម្ចាស់។

កូនឈើដែលបានយកមកដាំ ក្នុងតំបន់ព្រៃការពាររបស់សហគមន៍ គ្រប់គ្រងព្រៃឈើក្បាលខ្លា ក្នុងតំបន់ព្រៃឡង់នេះមាន៖ កកោះ បេង ក្រញូង នាងនួន និងគគីជាដើម។

ការធ្វើដំណើរ ទៅដល់កន្លែងដាំសម្រាប់អ្នកមិនធ្លាប់ចូលក្នុងព្រៃ គឺពិតជាមានការលំបាក ត្រូវធ្វើដំណើរតាមគោយន្តលើផ្លូវឆ្ងាយលំបាក រុកក្នុងព្រៃចូលទៅដល់កន្លែងដែលអាចចូលបាន។ កន្លែងខ្លះ គោយន្តមិនអាចចូលបានឡើយ គឺម្នាក់ៗត្រូវកាន់កូនឈើ តាមចំនួនដែលខ្លួនអាចកាន់បាន ធ្វើដំណើរដោយថ្មើរជើង រុកកាត់ព្រៃចូលទៅដាំនៅកន្លែងវាល ដែលត្រូវបានគេកាប់បំផ្លាញ ចំងាយផ្លូវប្រមាណ១គីឡូម៉ែត្រទៅមក។ លោក ហឿន សុភាព សកម្មជន បណ្ដាញស្ទួលព្រៃឡង់ បាននិយាយថា៖ ពិតជាសំខាន់ណាស់ក្នុងការការពារ និងដាំកូនឈើឡើងវិញ ព្រោះឈើ មានប្រយោជន៍ ជួយកាត់បន្ថយកំដៅ និងស្រូបយកជាតិពុល។ សកម្មជនព្រៃ ឡង់រូបនេះបន្តថា ដោយការស្រឡាញ់ ព្រៃឈើលោកបានខិតខំអស់ពីសមត្ថ ភាព កំលាំងកាយចិត្តក្នុងការពារព្រៃចុងក្រោយនេះ។ សកម្មភាពរបស់លោក ធ្លាប់ទទួលបាន ការគម្រាមដល់ជីវិតជា ញឹកញយ តែលោកនៅតែតស៊ូទៅមុខ លោកថា៖ "ត្រូវតែខិតខំ ខ្ញុំមិនខ្លាចទេ ព្រោះប្រទេសយើងមានច្បាប់"ហើយ ច្បាប់ល្អមិនអាចកែសង្គមបានទេ គឺត្រូវតែចាប់ផ្ដើមកែពីខ្លួនយើងផ្ទាល់។

ចំណែកយុវជន ជាសមាជិកក្នុងសហគមន៍គ្រប់គ្រងព្រៃឈើ ក្បាលខ្លា ដែលបាន ចូលរួមដាំកូនឈើដែរនោះ និយាយថា៖ ការដាំកូនឈើនេះ វាមិនអាចទទួលផលភ្លាមៗ ដូចអ្វីដែល យើងបានបាត់បង់នោះទេ។ តែវាជា ផលប្រយោជន៍ សម្រាប់អ្នកជំនាន់ ក្រោយទៀត "ខ្ញុំខិតខំការពារ និងដាំ ឡើងវិញ គឺមិនមនៃសម្រាប់ប្រយោជន៍ខ្លួនឯងទេ"។ យុវជនរូបនេះថា ដោយមានឱកាសចូលរួមការពារត្រូវតែការពារ និងថែរក្សា ព្រោះ "ខ្ញុំស្រឡាញ់ធម្មជាតិនិងព្រៃឈើ"។

លោក គង់ សុខា ប្រធានសហគមន៍គ្រប់គ្រងព្រៃឈើក្បាលខ្លា ស្រុកសណ្ដាន់ ខេត្តកំពង់ធំ មានប្រសាសន៍ថា សហគមន៍នេះ បានទទួលការអនុញ្ញាតពីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ឱ្យគ្រប់គ្រង លើផ្ទៃដីព្រៃ ចំនួន ២១៦៦,៨៨ ហិចតា។ ក្រោយពីកាត់ឲ្យប្រជាជននៅសល់ចំនួន ១២០០ ហិចតា ដែលជាដីព្រៃឈើពេលនេះកំពុងចាប់ផ្ដើមកំណត់ព្រំដី។ លោកថា ព្រៃនេះមានប្រយោជន៍ សម្រាប់ទុកឲ្យប្រជាជនក្នុងសហគមន៍ អាស្រ័យផល និងការពារ ទុកជាប្រយោជន៍សម្រាប់ក្មេងជំនាន់ក្រោយ។ ទោះជាយ៉ាងណាបទល្មើសព្រៃឈើ នៅតែកើតមានមិនដាច់។ លោកបន្តថា៖ អាជ្ញាធរហាក់ដូចជាព្រងើយកន្តើយ ចំពោះពាក្យបណ្ដឹងនានារបស់សហគមន៍។

ចំណែកលោក ចាន់ មន្នីនាថ នាយសង្កាត់រដ្ឋបាលព្រៃឈើសណ្ដាន់ បានថ្លែងថា អ្នកជំនាញរបស់លោក បានខិតខំយ៉ាងខ្លាំង ក្នុងការទប់ស្កាត់បទល្មើសទាំងនោះ ដោយស្រុកបានរៀបចំក្រុមការងារ ដើម្បីស្ទាក់ចាប់ជនល្មើស។ ម្យ៉ាងទៀត កម្លាំងរបស់លោក ក៏បានល្បាតជាច្រើនកន្លែងនៅព្រៃឡង់នេះ ។ ករណីខ្លះយឺតយ៉ាវ ព្រោះកម្លាំងលោកមានចំនួនតិច ហើយមានការងាររវល់ច្រើន។

លោកបន្តថា កន្លងមកខាងសង្កាត់រដ្ឋបាលព្រៃឈើ ក៏បានល្បាត និងសហការជាមួយសហគមន៍ ក្នុងកិច្ចការពារព្រៃឈើនេះ។ លោកបន្តថា នៅក្នុងស្រុកសណ្ដាន់មានសហគមន៍ចំនួន១០ ក្នុងនោះពីរសហគមន៍បានទទួលស្គាល់ពីក្រសួង និងប្រាំបីទៀតមិនទាន់មានការទទួលស្គាល់នៅឡើយទេ។

ព្រៃឡង់មានផ្ទៃដី ទំហំប្រមាណ ៣៦០០ គីឡូម៉ែត្រក្រឡា ស្ថិតនៅភាគខាងជើង នៃប្រទេសកម្ពុជា គ្រប់ដណ្ដប់លើខេត្ត កំពង់ធំ ព្រះវិហារ ក្រចេះ និងខេត្តស្ទឹងត្រែង មានប្រជាជនរស់ក្នុងតំបន់នេះ មានចំនួនប្រមាណជា ២០០.០០០នាក់ ភាគច្រើនជាជនជាតិភាគតិចគួយ។ *ដោយលី សុវណ្ណា*







*ប្រជាសហគមន៍និងបុគ្គលិកអង្គការជេស្វីតសឺវីសកម្ពុជាដាំដើមឈើនៅតំបន់ព្រៃឡង់ ក្នុងខេត្តកំពង់ធំ។ រូបថតៈ លី សុវណ្ណា*

# អាពាហ៍ពិពាហ៍ជាតម្លៃមួយទោះចង់ឬមិនចង់ ខ្មែរមិនអាចអត់ចំណាងនេះបានទេ



*លោកស្រី តែ កលិកា ប្រធានក្រុមហ៊ុនរៀលហ្គោល អ៉ីងវេន មេនេចមេន។ បុត្រ*

*អាពាហ៍ពិពាហ៍ គឺជាតម្លៃនៃចំណងគ្រួសារមួយ ដើម្បីឲ្យទទួលបាននូវការទទួលស្គាល់ពីសង្គម ប៉ុន្តែដោយសារលក្ខខណ្ឌនៃសង្គម - សេដ្ឋកិច្ច មានការប្រែប្រួល វាអាចមានការផ្លាស់ប្តូរ ដូច្នេះ ដើម្បីឲ្យយល់អំពីចំណងនេះ និងបញ្ហាមួយចំនួនជុំវិញការរៀបចំពិធីនេះ អ្នកនាំសារ បានជួបសំភាសន៍ជាមួយនឹងអ្នកស្រី តែ កលិកា ប្រធានក្រុមហ៊ុនរៀលហ្គោល អ៉ីវេន មេនេចមេន ដែលជាក្រុមហ៊ុនមួយ រៀបចំពិពណ៌អាពាហ៍ពិពាហ៍ ដើម្បីពន្យល់អំពីចំណងនេះនិងបញ្ហាពាក់ព័ន្ធនឹងការទទួលបានចំណងនេះ។*

**អ្នកនាំសារ ៖** តើហេតុអ្វី បានជាក្រុមហ៊ុនរបស់លោកស្រី មានចំណាប់អារម្មណ៍រៀបចំ ជាពិពណ៌អាពាហ៍ ពិ-ពាហ៍ជារៀងរាល់ឆ្នាំបែបនេះ?

**លោកស្រី តែ កលិកា ៖** គោលបំណងគឺចង់បង្ហាញ អំពីតម្លៃនៃចំណងអាពាហ៍ពិពាហ៍ ក៏ដូចជាសម្លៀកបំពាក់ប្រពៃណីខ្មែរ និងទំនៀមទំលាប់វប្បធម៌ នៃការរៀបចំពិធីនេះ តាំងពីដើមរហូតដល់ចប់ ដោយសារតែបច្ចុប្បន្ននេះ ការរៀបចំពិធីនេះ គឺហាក់មិនសូវត្រឹមត្រូវ ទៅតាមក្បួនខ្នាតរបស់ខ្មែរយើង ដូច្នេះ ហើយបានជាក្រុមហ៊ុន បានសំរេចចិត្តសហការជាមួយនឹងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ព្រមទាំងក្រសួងធម្មការ និងកិច្ចការសាសនា ដើម្បីរៀបចំពិពណ៌នេះឡើង។

**អ្នកនាំសារ ៖** តើកម្មវិធីពិពណ៌ ដែលមានរយៈពេល៣ថ្ងៃ ពីថ្ងៃទី០៧ ដល់ ០៩ ខែសីហា នៅមជ្ឈមណ្ឌលសន្និបាត និងពិពណ៌កោះពេជ្រនេះ ទទួលបានការចូលរួម តាំងពិពណ៌ ពីក្រុមហ៊ុនប៉ុន្មាន?

**លោកស្រី តែ កលិកា ៖** បណ្តាក្រុមហ៊ុនដែលចូលរួមតាំងពិពណ៌ គឺមានសរុបប្រមាណជា២០០ស្តង់ ហើយក្រុមហ៊ុនដែលចូលតាំងបង្ហាញ គឺមានដូចជា ខាងក្នុង ផលិតផលគ្រឿងសំអាងការ អលង្ការ ភេសជ្ជៈ សណ្ឋាគារ។ល។ ពិពណ៌នេះ បានទាក់ទាញភ្ញៀវចូលរួមប្រមាណជាពី ៤០.០០០ នាក់ទៅ ៦០.០០០នាក់ នៅក្នុងនោះ ប្រហែលជា៤០ភាគរយ ជាយុវជន និងយុវនារី ភ្ញៀវទេសចរណ៍ប្រហែលជា ៥ភាគរយដែរ។

**អ្នកនាំសារ ៖** លក្ខខណ្ឌសេដ្ឋកិច្ចសង្គមឥឡូវ គឺមានការប្រែប្រួល សង្គមកម្ពុជា ក៏មានការប្រែប្រួល ហើយជាទូទៅ មកដល់ពេលនេះ ការចំណាយសម្រាប់ពិធីនេះគឺខ្ពស់ ដូច្នេះលោកស្រីយល់យ៉ាងម៉េចដែរអំពីបញ្ហានេះ?

**លោកស្រី តែ កលិកា ៖** ជាការពិតការចំណាយអាពាហ៍ពិពាហ៍ នៅពេលបច្ចុប្បន្ននេះ គឺពិតជាខ្ពស់ ហើយតាមអ្វីដែលខ្ញុំសង្កេត គឺយើងភាគច្រើនចំណាយខ្ជះខ្ជាយច្រើន ទៅលើម្ហូបអាហារ សំលៀកបំពាក់ និងការតុបតែង ដូច្នេះបើសិនជាអាច គូស្វាមីភរិយា គួររិះគិតចំណុចនេះ ហើយអាចនឹងទៅពិភាក្សាជាមួយនឹងក្រុមហ៊ុន ដែលទទួលសេវារៀបចំគេអាចនឹងជួយបាន។

**អ្នកនាំសារ ៖** ជាទូទៅ តាមបទពិ-សោធន៍លោកស្រីផ្ទាល់ ជាអ្នកដែលរៀបចំកម្មវិធីពិពណ៌នេះ តើដើម្បីរៀបចំកម្មវិធីអាពាហ៍ពិពាហ៍ មួយបានសម-រម្យ តើគូរស្វាមីភរិយាថ្មោងថ្មីនេះ ត្រូវចំណាយប៉ុន្មាន?

**លោកស្រី តែ កលិកា ៖** តាមលក្ខខណ្ឌសេដ្ឋកិច្ចនាពេលបច្ចុប្បន្ននេះ ការចំណាយរបស់ប្រជាពលរដ្ឋខ្មែរទៅលើការរៀបចំពិធីអាពាហ៍ពិពាហ៍ គឺជាទូទៅនៅក្នុងកំរិតជាមធ្យម ប្រហែលជា ១០.០០០ដុល្លារឡើង ប៉ុន្តែក៏មានអ្នកខ្លះ គាត់អាចបង្រួមការចំណាយផ្សេងៗ ហើយមកនៅត្រឹម ប្រមាណជា ៥.០០០ ដុល្លារដែរក៏មានដែរ។ ក្រៅពីនោះ ក៏មានអ្នកដែលមានធនធានខ្លះ ចំណាយរហូតដល់ទៅជាង ១០០.០០០ ដុល្លារក៏មានដែរ។ ពោលជាទូទៅ ការចំណាយនេះគឺទៅតាមធនធាន នៃគ្រួសារ របស់គូស្វាមីភរិយាថ្មោងថ្មីនោះផ្ទាល់ នៅក្នុងនោះ សេវាកម្មដែលចំណាយខ្ពស់បំផុត គឺម្ហូបអាហារ និងការតុបតែងផ្កា។

**អ្នកនាំសារ ៖** នៅក្នុងលក្ខខណ្ឌសេដ្ឋ-កិច្ចសង្គមយើងសព្វថ្ងៃនេះ សោហ៊ុយនៅក្នុងការចំណាយ ទៅលើចំណងអាពាហ៍ពិពាហ៍នេះគឺខ្ពស់ ដូច្នេះដើម្បីឲ្យយុវជន និង យុវនារីដែលមានគម្រោងចាប់ដៃគ្នា កសាងនូវគ្រួសារមួយ មានការទទួលស្គាល់ពីសង្គមថា តើពួកគេគួរត្រៀមខ្លួនយ៉ាងណា ?

**លោកស្រី តែ កលិកា ៖** ថ្វីត្បិតសោហ៊ុយ នៃការចំណាយទៅលើការរៀបចំពិធីអាពាហ៍ពិពាហ៍នេះវាខ្ពស់ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ដើម្បីរៀបចំពិធីនេះបានសមរម្យ គឺយុវជន និងយុវនារី អាចអនុវត្តជាការសន្សំថវិការ និងខិតខំធ្វើការ ហើយព្យាយាមកាត់បន្ថយការចំណាយផ្សេងៗ។

**អ្នកនាំសារ ៖** ចុះបើពួកគេមិនមានលទ្ធភាពទាល់តែសោះ ដោយសារសោហ៊ុយនេះវាខ្ពស់ តើមានវិធីសាស្រ្តអ្វី ដើម្បីឲ្យ ពួកគេអាចរស់នៅក្នុងនាមជាគូស្វាមីភរិយា ដែលមានការទទួលស្គាល់ពីសង្គម?

**លោកស្រី តែ កលិកា៖** ជាទូទៅ នៅកម្ពុជានាពេលបច្ចុប្បន្ននេះ ការចាប់ដៃគ្នាកសាងជីវិតគ្រួសារ ដោយមិនមានចំណងអាពាហ៍ពិពាហ៍ គឺមិនមានជាបញ្ហាអ្វីនោះទេ ប៉ុន្តែបើនិយាយអំពីតម្លៃនៃការទទួលស្គាល់ពីសង្គម គឺអាចនៅមានបញ្ហា គឺគាត់អាចទៅចុះសំបុត្រអាពាហ៍ពិពាហ៍ជាការស្រេច ប៉ុន្តែតាមយោបល់របស់នាងខ្ញុំ ពួកគេគួរតែរៀបចំជាពិធីតូចមួយដើម្បីឲ្យចាស់ទុំ ដូនតា សាច់ញាតិដឹងឮ ។

*ដោយអរិយបុត្រ*

## ច្បាប់ចរាចរណ៍ផ្លូវគោកថ្មី

**មាត្រាទី២៣៖**

ហាមឈប់ ឬចតយានជំនិះនៅទីកន្លែងដូចខាងក្រោម (ត)៖

លើច្រកចេញចូល នៃអគារសា-ធារណៈ

នៅលើទ្រូងផ្លូវមុខច្រកចេញចូលផ្ទះឯកជន លើកលែងតែយានរបស់ម្ចាស់ផ្ទះដែលជាកម្មសិទ្ធិតែមួយ

ជាពីរជួរទន្ទឹមគ្នា

នៅលើគែមទ្រូងផ្លូវម្ខាង បើនៅគែមម្ខាងទៀតដែលឈមមុខគ្នា ជាកន្លែង ទុកសម្រាប់ឲ្យយានជំនិះចត លើកលែងតែក្នុងករណី ដែលអាចចតបានទាំងសងខាង

នៅកន្លែងដែលមាន សញ្ញាហាមឈប់ ឬហាមចត

នៅលើទ្រូងផ្លូវលើសពី ២៤ ម៉ោង

នៅចន្លោះតិចជាង ១០ (ដប់) ម៉ែត្រពីមុខ និង ពីក្រោយផ្លាកសញ្ញាកន្លែងរបស់រថយន្តក្រុងឈប់

នៅចន្លោះតិចជាងមួយម៉ែត្រ ពីមុខ ឬពីក្រោយរថយន្តដែលឈប់ ឬចតបន្តកន្ទុយគ្នា

នៅជិតផ្លូវប្រសព្វ ឬផ្លូវបត់។

**មាត្រាទី២៥៖**

ហាមបត់ត្រឡប់ក្រោយ ក្នុងករណីដូចខាងក្រោម៖

នៅជិតផ្លូវប្រសព្វ ឬជិតផ្លូវរថភ្លើងឆ្លងកាត់

នៅត្រង់ផ្លូវកោង ដែលអ្នកបើកបរមិនអាចមើលឃើញយានផ្សេងៗ ទៀតបានក្នុងចម្ងាយ ១៥០ (មួយរយហាសិប)ម៉ែត្រ

នៅជិតដល់កំពូលខ្ពស់ និង នៅពេលចុះពីកំពូលខ្ពស់

នៅកន្លែងដែលមានសញ្ញាហាមបត់ត្រឡប់ក្រោយ

នៅលើទ្រូងផ្លូវឯកទិស។

វិធានខាងលើនេះ ត្រូវបានលើកលែងពេលមានសញ្ញាបញ្ជារបស់នគរ-បាលចរាចរណ៍ផ្លូវគោក ឬ គំនូសសញ្ញាចរាចរណ៍នៅទ្រូងផ្លូវ។



*រូបថត: DR*



*កម្មករ-ការិនី ធ្វើដំណើរមកផ្ទះដោយឡានឈ្នួលដឹកទំនិញ ។*

# កម្មករនិងកម្មការិនីរោងចក្រកាត់ដេរច្រើនប៉ុន្តែខ្វះទំនាក់ទំនងគ្នា

ឃើញដើរចេញ ដើរចូលរោងចក្រទាំងហ្វូងៗ ប៉ុន្តែនៅពេលដែលសាកសួរគ្នាទៅ កម្មករ និងកម្មការិនី គឺច្រើនមិនស្គាល់គ្នាឡើយ។ នេះគឺជាស្ថានភាពពិតនៃកម្មករ និងកម្មការិនី ដែលកំពុងតែបំរើការ នៅក្នុងឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ និងស្បែកជើងនៅកម្ពុជានាពេលបច្ចុប្បន្ន។

កញ្ញា ហាប សុចន្ទី ជាកម្មកររោងចក្រមួយកន្លែង នៅម្តុំផ្លូវ ៣៧១ សង្កាត់សន្សំកុសល ខណ្ឌមានជ័យ បានឲ្យដឹងថា កម្មកររោងចក្រច្រើនណាស់កញ្ញមិនអាចស្គាល់អស់នោះទេ ។

កញ្ញា បានឲ្យដឹងថា នៅក្នុងចំណោមកម្មករ និងកម្មការិនីដែលធ្វើការនៅរោងចក្រតែមួយជាមួយគ្នា កញ្ញា ស្គាល់តែនៅក្នុងក្រុមការងារ ៤ទៅ ១០ នាក់ប៉ុណ្ណោះ ។

កញ្ញា បានបញ្ជាក់ថា "ស្គាល់ម៉េចអស់ បើមនុស្សរាប់រយនាក់បែបនេះ"។

យុវតីដែលមានវ័យ២២ ឆ្នាំរូបនេះ បានឲ្យដឹងថា នៅក្នុងចំណោមកម្មករ និងកម្មការិនីរោងចក្រទាំងអស់ ដែលកញ្ញាបានស្គាល់ គឺមានតែអ្នកមកពីស្រុកភូមិជាមួយគ្នា ក្រៅពីនេះ គឺមានអ្នកបើកលុយ សន្តិសុខ ប៉ុន្តែក៏មិនប្រាកដថា អ្នកដែលកញ្ញាបានស្គាល់នោះ គេស្គាល់កញ្ញាអស់ដែរ ។

កញ្ញា ហេង រស្មី ជាកម្មការនីរោងចក្រកាត់ដេរមួយរូបទៀត នៅម្តុំតែមួយក៏បានឲ្យដឹងទៀតថា កម្មករនិងកម្មការិនីទាំងអស់ មិនអាចស្គាល់គ្នាអស់ទេ ដោយសារតែម្នាក់ៗ ពេលទៅធ្វើការ គឺឈ្ងោកមុខរៀងខ្លួន ហើយបើចូលទៅបន្ទប់ទឹកវិញ គឺសឹងតែដូចរត់ ខ្លាចស្ទះការងារគេ។

ស្រ្តីជាកម្មការិនីរោងចក្ររូបនេះ បានបញ្ជាក់ថា "រាល់ថ្ងៃនេះ បើមានទំនាក់ទំនង និយាយលេងសើចអី គឺតែជាមួយនឹងក្រុមការងារមួយក្រុម ១០ នាក់អីប៉ុណ្ណោះ"។

កញ្ញា បានឲ្យដឹងថា ធ្វើការនៅក្នុងរោងចក្រ គឺត្រូវបានបែងចែកជាក្រុមៗ គឺមានក្រុមដេរក ក្រុមដេភ្ជាប់ ក្រុមដេរដៃអាវ ក្រុមអ៊ុត ក្រុមកាត់ដេស។ល។

កញ្ញា បានបន្តទៀតថា តាំងពីអាយុ ១៩ឆ្នាំមកដល់ ២៣ នៅក្នុងឆ្នាំនេះ កញ្ញា បានធ្វើការនៅរោង ចក្របាន ៤ រោងចក្រហើយ ប៉ុន្តែរឿងការងារ គឺបែងចែកដូចតែគ្នាតែឥចឹង ។

លោក សេង សាញ់ ជាកម្មករនៅរោងចក្រផលិតទឹកកកមួយកន្លែង បានឲ្យដឹងថា ធ្វើការនៅរោងចក្រ គឺពិបាកស្គាល់គ្នាអស់ណាស់ ដោយសារតែមនុស្សវាច្រើន ហើយម្នាក់ៗ គិតតែខំធ្វើការ នឹងអាចលើសបុង បានប្រាក់បន្ថែមខ្លះ ដែលខុសពីកន្លែងរោងចក្រទឹកកក មនុស្សតែបួន១០នាក់នោះ ។

លោក សាញ់ បានអះអាងថា "កាលខ្ញុំធ្វើការជាអ្នកបោកគក់ នៅរោងចក្រកាត់ដេរ គឺខ្ញុំស្គាល់តែក្រុមការងារខ្ញុំ តែបួនប្រាំនាក់ហ្នឹង"។ លោកបានបញ្ជាក់ទៀតថា "ស្គាល់ឯណាអស់ បើម៉ារោងចក្រ គឺមនុស្ស ៥០០ នាក់ ទៅ ៦០០ នាក់ឯណោះ បើក្រុមផ្សេងវិញ គឺយ៉ាងច្រើន ស្គាល់មួយនាក់ទៅពីរ ដែលយើងចាប់អារម្មណ៍ប៉ុណ្ណោះ"។

លោកបានបន្តថា ស្ថានភាពការងារនៅរោងចក្រមនុស្សវាច្រើន ដូច្នេះហើយទើបបានជាពិបាកស្គាល់គ្នា តែដល់ពេលធ្វើការនៅរោងចក្រទឹកកក រឿងអីមិនស្គាល់គ្នា បើមនុស្សត្រឹមតែ១០ ទៅ ២០នាក់នោះ ។

លោកបានបញ្ជាក់ថា "ពេលធ្វើការតាមរោងចក្រមានអារម្មណ៍ថា ដូចជាមនុស្សយន្ត ពោលគឺធ្វើដដែលៗ ម៉ាថ្ងៃទល់យប់ មួយខែ៣០ថ្ងៃ គឺមានតែធ្វើការសម្រាកដេកតែប៉ុន្នឹង"។

លោកបានបន្តទៀតថា ស្គាល់គ្នាច្រើនចឹងទៅក៏ម្យ៉ាង ដោយសារតែពេលមានទុក្ខធុរៈអី គឺយើងចេះជួយគ្នា តែបើនៅរោងចក្រ ពេលដាច់លុយអី ពិបាកខ្ចីគ្នាណាស់ ដោយសារតែមិនសូវស្គាល់។

ជុំវិញបញ្ហានេះ មន្ត្រីនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមួយរូប ដែលសុំមិនបញ្ចេញឈ្មោះ បានឲ្យដឹងថា ទំនាក់ទំនងសង្គមវាល្អប្រសើរណាស់ ប៉ុន្តែបើសិនជាចូលធ្វើការរោងចក្រ គឺភាគច្រើន គេតម្រូវឲ្យធ្វើការដូចជាមនុស្សយន្តតែម្តង ។

លោកបានបន្តទៀតថា នៅក្នុងស្រុកយើង គឺមានករណីលើកលែងខ្លះ ប៉ុន្តែបើនៅស្រុកគេវិញ ដូចជានៅឥណ្ឌា បង់ក្លាដេស ហើយសូម្បីតែនៅប្រទេសធំៗ ដូចជាអូស្ត្រាលីអី ពេលធ្វើការ ដឹងតែពីធ្វើការ ។

លោកបានបញ្ជាក់ថា "ខ្ញុំឃើញនៅស្រុកយើង ពេលធ្វើការ កម្មករអាចមានពេលនិយាយលេងសើច ចំអែចំអន់គ្នាខ្លះបាន តែនៅស្រុកគេ គឺអត់មានពេលតែម្តង គឺថាតែធ្វើការ ៤ម៉ោង គឺរវៃ៤ម៉ោងតែម្តង ដោយសារតែអវត្តមានយើងមួយ ត្រឹមតែ១នាទី គឺខូចខ្សែរសង្វាក់ផលិតកម្មគេរាប់សិប"។

លោកបានបន្តទៀតថា នៅក្នុងពេលធ្វើការ ប្រសិនបើកម្មករ និងកម្មការិនីនៅពេលសម្រាក ចេញស្គាល់គ្នា រាប់អានគ្នា គឺល្អ ងាយនឹងទទួលបានព័ត៌មានច្រើន ខណៈដែលបច្ចុប្បន្ននេះ គឺកម្មករច្រើនតែទទួលព័ត៌មាន ពីសហជីព ដែលជួនកាល ជាព័ត៌មានខ្វះការផ្ទៀងផ្ទាត់។

គិតត្រឹមដំណាច់ត្រីមាសទីមួយ នៅក្នុងដើមឆ្នាំ ២០១៥ កន្លងមកនេះ អង្គការពលកម្មអន្តរជាតិ បានឲ្យដឹងថា កម្ពុជា មានរោងចក្រកាត់ដេរទាំងអស់សរុបចំនួន ៦៤០ រោងចក្រ នៅក្នុងនោះ បានផ្តល់ការងារធ្វើ រហូតដល់ទៅ ៦០៥.១០០ នាក់ ។

ផ្អែកតាមតួលេខនេះ ជាមធ្យមនៅក្នុងរោងចក្រនីមួយៗ គឺអាចមានកម្មករ និងកម្មការិនី ប្រមាណជាជាង ៩០០ នាក់ធ្វើការ៕

*ដោយអរិយបុត្រ*

## គណបក្ស នយោបាយ កើតថ្មីព្រោងព្រាត

នៅចុងខែកក្កដា និង ដើមខែសីហា យ៉ាងហោចណាស់គណបក្សនយោបាយថ្មី៣ បានកើតឡើង បន្ទាប់ពីគណបក្សសំបុកឃ្មុំ សង្គមប្រជាធិបតេយ្យ របស់លោក ម៉ម សូណង់ដូ អគ្គនាយកវិទ្យុសំបុកឃ្មុំ ។

គណបក្ស ដែលបានប្រកាសចេញនោះ គឺមានគណបក្សអំណាច ពល - រដ្ឋខ្មែរ ដែលបង្កើតឡើង ដោយលោក សួន សេរីរដ្ឋា អតីតប្រធានចលនាអំណាចពលរដ្ឋខ្មែរ ដែលត្រូវបានតុលាការកាត់ទោស ឲ្យជាប់ពន្ធនាគារ ៧ឆ្នាំ និង ពិន័យជាប្រាក់ចំនួន២៥ លានរៀល ពាក់ព័ន្ធពីបទរួមគំនិតក្បត់ជាតិ ប៉ុន្តែត្រូវបាន ប្រមុខរដ្ឋាភិបាលស្នើសុំការលើកលែងទោស ។

ក្រៅពីនេះ គណបក្សមួយទៀត គឺគណបក្ស ប្រជាធិបតេយ្យមូលដ្ឋាន ដែលដឹកនាំដោយលោក យ៉េង វីរៈ អតីតនាយកប្រតិបត្តិ នៃអង្គការមជ្ឈមណ្ឌលអប់រំច្បាប់សហគមន៍ និងគណបក្សមួយទៀត គឺគណបក្សខ្មែរសាមគ្គី ដែលបង្កើតឡើងដោយ អតីតក្រុមអ្នកគាំទ្រ គណបក្សសង្គ្រោះជាតិ ។

នៅស្របពេលនឹង និន្នាការនយោបាយចុងក្រោយនេះ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា នៅក្នុងពិធីសម្ពោធស្ពានមិត្តភាពកម្ពុជា-ចិន(តាខ្មៅ) បានថ្លែងថា កាលបោះឆ្នោតជាតិអាណត្តិក្រោយនេះ នឹងប្រព្រឹត្តទៅដដែល គឺនៅថ្ងៃអាទិត្យសប្តាហ៍ទី៤ នៃខែកក្កដា ឆ្នាំ២០១៨ ដោយឡែក ។

# ប្រមុខរដ្ឋាភិបាល ដាក់បទ បញ្ជាឲ្យតាមរកបាតុករ ហិង្សានៅទីលាន ប្រជាធិបតេយ្យមកជំនុំជម្រះ

សម្តេចតេជោ ហ៊ុន សែន កាលពីថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៥ បានប្រកាសពីការចេញបទបញ្ជា ឲ្យអាជ្ញាធរតាមចាប់ឲ្យអស់មេដឹកនាំ ដែលជាសកម្មជន គណបក្សសង្គ្រោះជាតិ ដែលធ្វើបាតុកម្ម ហិង្សាមកលើក្រុមសន្តិសុខ កាលពីថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០១៤ ។

សម្តេចតេជោ ហ៊ុន សែន បានមានប្រសាសន៍ថា បទបញ្ជារបស់លោក បានចេញរួចហើយ ទៅអគ្គស្នងការនគរបាលជាតិ និងអភិបាលរាជធានីភ្នំពេញ ដើម្បីតាមចាប់ឲ្យអស់បាតុករ ថ្ងៃ១៥កក្កដា ( ឆ្នាំ២០១៤ )។

សម្តេចតេជោ ហ៊ុន សែន បានមានប្រសាសន៍ថា មិនទាន់អស់ទេ ពិសេស ស្ត្រីម្នាក់ដែលជាក់គេ។ អ្នកទាំងនោះ មានមុខ ក្នុងខ្សែអាត់វិដេអូអស់ហើយ មិនតែប៉ុណ្ណោះ ក៏បានព្រមានដល់តំណាងរាស្ត្រ ៧រូប របស់គណបក្សសង្គ្រោះជាតិ ត្រូវទៅតុលាការ បើសិនជាមានដីកាកោះហៅ ហើយមានប្រសាសន៍ទៀតថា បើមិនដូច្នោះទេ គឺពួកគេអាចប្រឈមនឹងការ កាត់ទោសកំបាំងមុខ។

សម្តេចតេជោ ហ៊ុនសែន ក៏បានគូសបញ្ជាក់ជាថ្មីថា ការសន្ទនាតាមនយោបាយ មិនអាចដោះស្រាយបញ្ហានៅតុលាការបានទេ។

សំណុំរឿងបាតុកម្ម រំដោះទីលានប្រជាធិបតេយ្យ ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៤ ត្រូវបានតុលាការសាលាដំបូងរាជធានីភ្នំពេញ កាលពីថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៥ បានសម្រេចផ្តន្ទាទោស ដាក់ពន្ធនាគារលើសកម្មជនគណបក្សសង្គ្រោះជាតិ ១១ នាក់ឲ្យជាប់ពន្ធនាគារ ពី៧ ទៅ ២០ឆ្នាំ ពីបទប្រើប្រាស់អំពើហិង្សា បណ្តាលឲ្យក្រុមសន្តិសុខខណ្ឌដូនពេញ របួស៣៨ នាក់ក្នុងពេលធ្វើបាតុកម្ម ៕

# ឆមាសទីមួយដើមឆ្នាំ២០១៥ កម្ពុជាទាក់ទាញវិនិយោគទុនបានប្រមាណជា ៣.១២៨ លានដុល្លារ

នៅឆមាសទីមួយដើមឆ្នាំ ២០១៥ កន្លងទៅនេះ មន្ត្រីជាន់ខ្ពស់កម្ពុជាមួយរូប បានអះអាងថា កម្ពុជាបានទាក់ទាញទុនវិនិយោគមានតម្លៃសរុប ប្រមាណជា ៣.១២៨ លានដុល្លារ ។

យោងទៅតាមបទបង្ហាញរបស់លោក ស៊ុន ចាន់ថុល ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ទៅកាន់ក្រុមអ្នកវិនិយោគទុន មកពីម៉ាកាវចំនួន ៤២ រូបកាលពីពេលថ្មីៗនេះ បានឲ្យដឹងថា ទំហំវិនិយោគ នៅឆមាសទីមួយឆ្នាំ ២០១៥ នេះ គឺមានតម្លៃច្រើនជាង ទំហំទឹកប្រាក់វិនិយោគកាលពីឆ្នាំ២០១៤ កន្លងទៅ ។

លោកបានឲ្យដឹងថា កាលពីឆ្នាំ ២០១៤ កម្ពុជាបានទទួលគម្រោងវិនិយោគមានតម្លៃត្រឹមតែ ១.៦១០ លានដុល្លារតែប៉ុណ្ណោះ ខណៈដែលកាលពីឆ្នាំ២០១៣ គឺទទួលបានប្រមាណជា ៤.៤៨៣ លានដុល្លារ ឆ្នាំ២០១២ គឺ ២.២៧៧ លានដុល្លារ ។

លោក រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មរូបនោះ បានបន្តទៀតថា នៅក្នុងរយៈពេលពីឆ្នាំ១៩៩៤ ដល់ខែមិថុនា ឆ្នាំ ២០១៥ កម្ពុជាបានទាក់ទាញវិនិយោគទុនធំៗចំនួន ១១ ដោយចិននាំមុខគេ ហើយជប៉ុន គឺនៅលំដាប់ចុងក្រោយគេ។

ប្រភពដដែលបានបន្តទៀតថា នៅក្នុងរង្វង់ពីឆ្នាំ១៩៩៤ ដល់ខែមិថុនា ឆ្នាំ ២០១៥ តម្លៃវិនិយោគទុនពីចិន គឺមានតម្លៃសរុប ១០.៣០១លានដុល្លារ កូរ៉េខាងត្បូងនៅលំដាប់ទីពីរ ជាមួយនឹងតម្លៃវិនិយោគសរុប ៤.៤៧១ ដុល្លារ សហគមន៍អឺរ៉ុបគឺទីបី ដែលមានតម្លៃសរុប ៣.៧៧២លានដុល្លារ ម៉ាឡេស៊ីទី៤ គឺ២.៦៥០ លានដុល្លារ ។

ប្រភពដដែល បានបន្តទៀតថា សម្រាប់វៀតណាម គឺនៅលំដាប់ទី៥ ជាមួយនឹងទុនវិនិយោគសរុប ១.៥៦៨ លានដុល្លារ អាមេរិកលំដាប់ទី៦ ជាមួយនឹងទុន ១.៣១១ លានដុល្លារ តៃវ៉ាន់ឈរនៅលំដាប់ទី ៧ ជាមួយនឹងទុកវិនិយោគសរុប ១.១១៦ លានដុល្លារ៕

# ចំនួនប្រជាពលរដ្ឋពិភពលោកនឹងកើនដល់៩,៧ ពាន់លាននាក់ នៅឆ្នាំ២០៥០

ការសិក្សាមួយ របស់អង្គការសហប្រជាជាតិ បានឲ្យដឹងថា នៅពេលនេះ ចំនួនប្រជាពលរដ្ឋនៅទូទាំងពិភពលោក គឺមានចំនួន ប្រមាណជា៧,៣ពាន់លាននាក់ ប៉ុន្តែនៅឆ្នាំ២០៥០ គេបានព្យាករណ៍ថា នឹងកើនដល់ ៩,៧ ពាន់លាននាក់ និងនៅឆ្នាំ២១០០ នឹងកើនដល់ទៅ១១,២ពាន់លាននាក់ ។

របាយការណ៍ដដែល បានឲ្យដឹងទៀតថា ប្រទេសឥណ្ឌាដែលបច្ចុប្បន្នមានប្រជាពលរដ្ឋច្រើនជាងគេ លំដាប់ទីពីរ នឹងដណ្តើមតួនាទីលេខមួយនៅក្នុងឋានៈជាប្រទេស ដែលមានប្រជាពលរដ្ឋ ច្រើនជាងគេនៅក្នុងរង្វង់ឆ្នាំ ២០២២ ។

ក្រៅពីចិនចេញនោះ នីហ្សេរីយ៉ា នឹងដណ្តើមអាមេរិក ដែលជាប្រទេសមានប្រជាជនច្រើនជាងគេ លំដាប់ទី៣ នៅបច្ចុប្បន្ន នៅក្នុងរង្វង់ឆ្នាំ២០៥០។

របាយការណ៍នេះ បានឲ្យដឹងថា អាហ្វ្រិក គឺជាកន្លែងនៃប្រភពកំណើនប្រជាពលរដ្ឋប្រហែលជា ពាក់កណ្តាលនៃប្រជាជននៅលើពិភពលោក នៅក្នុងរង្វង់៣៥ឆ្នាំខាងមុខនេះ។

ប្រភពដដែលបានបន្តទៀតថា នៅក្នុងអំឡុងឆ្នាំ ២០១៥ ទៅ ២០៥០ ប្រទេសដែលនឹងមានកំណើន ប្រជាពលរដ្ឋច្រើនបំផុត នៅលើពិភពលោកនេះគឺមាន ឥណ្ឌា នីហ្សេរីយ៉ា ប៉ាគីស្ថាន សាធារណរដ្ឋប្រជាធិបតេយ្យ កុងហ្គោ អេត្យូពី តង់ហ្សានី អាមេរិក ឥណ្ឌូនេស៊ី និង អូហ្គង់ដា ៕

# វាចារបស់រាស្ត្រ ៖ បញ្ហាព្រំដែនជារឿងត្រូវ



*ប្រជាពលរដ្ឋនិងតំណាងរាស្ត្រនាំគ្នាទៅពិនិត្យព្រំដែនកម្ពុជាវៀតណាម។ រូបថតៈ សហ*

## " កិច្ចការដោះ ស្រាយបញ្ហាព្រំដែននេះ ទាមទារ ពេលវេលា និងការជជែកគ្នាច្រើន ដើម្បី កុំឲ្យវាមានទំនាស់ "

ប្រជាពលរដ្ឋកម្ពុជា ជាទូទៅ បានចាត់ទុកថា បញ្ហាព្រំដែនជារឿងដែលត្រូវដោះស្រាយជាបន្ទាន់។ វាសម្រេចបានលុះត្រាតែកម្ពុជារួមគ្នា ជាធ្លុងមួយ និងមានជំហរមួយច្បាស់លាស់។ រីឯរដ្ឋាភិបាលបាន

លោក ង៉ែត ច័ន្ទតារា ជាប្រជាពលរដ្ឋមួយរូប ដែលរស់នៅក្នុងខណ្ឌសែនសុខ រាជធានីភ្នំពេញ បានឲ្យដឹងថា មួយរយៈនេះ លោកហាក់ដូចពេញចិត្តណាស់នឹងសន្ទុះការងារព្រំដែន ដែលអ្នកនយោបាយបានធ្វើ ប៉ុន្តែចុងក្រោយលោកដូចជាអស់សង្ឃឹមវិញ ដោយសារតែសញ្ញានៃការឈ្លោះគ្នារវាងអ្នកនយោបាយបានកើតចេញមកបន្តទៀត។

លោកបានបញ្ជាក់ថា "ហេ! ម៉ារយៈនេះ សកម្មមែនទែន ទាំងគណបក្សសង្គ្រោះ (គណបក្សសង្គ្រោះជាតិ) និងគណបក្សប្រជាជន (គណបក្សប្រជាជនកម្ពុជា)។ ខាងសង្គ្រោះ ជាអ្នកធ្វឹះ ហើយ ឃើញខាងប្រជាជន គឺជាអ្នកប្រតិបត្តិ"។

លោកបានបញ្ជាក់ទៀតថា "ឲ្យតែការងារវាដំណើរការតចឹង ខ្ញុំជឿថា បញ្ហាព្រំដែនប្រាកដជាដោះស្រាយបាន និងមានសុក្រិតភាព ប៉ុន្តែមានអីឥឡូវឈ្លោះគ្នាទៀតហើយ"។

នៅក្នុងរយៈពេល ប្រមាណជាមួយខែចុងក្រោយនេះ កិច្ចការព្រំដែនគឺហាក់ដូចជាមានសភាព ផុលផុសមែនទែន ហើយ គណបក្សទាំងពីរ ដែលមានអសនៈនៅក្នុងសភា គឺហាក់សកម្មនៅក្នុងការដោះស្រាយបញ្ហានេះ ដោយគណបក្សសង្គ្រោះជាតិ គឺជាអ្នកដែលស្វែងរក បញ្ហាអសកម្មនៅតាមព្រំដែន ហើយគណបក្សប្រជាជន ដែលកំពុងតែដឹកនាំស្ថាប័ននិតិប្រតិបត្តិកនៅក្នុងនាមជាគណបក្សឈ្នះឆ្នោតនោះ គឺបានអនុវត្ត និង ចាត់វិធានការជាបន្តបន្ទាប់ តាមរយៈ ការផ្ញើជាកំណត់ទូត រវាងប្រទេសកម្ពុជា និង វៀតណាម ក៏ដូចជារឿងកោះប្រជុំគណកម្មការ ទទួលបន្ទុកកិច្ចការ ព្រំដែនកម្ពុជា និងវៀតណាម ការស្នើសុំខ្ចីផែនទីពី អង្គការសហប្រជាជាតិ ពីអាមេរិក ពីបារាំង ដើម្បីផ្ទៀងផ្ទាត់ និងផែនទីដែលមានស្រាប់។ល។

លោក រិទ្ធ ស័ក្តរចនា ដែលអះអាងថាជាប្រជារាស្ត្រមួយរូប នៅក្នុងខណ្ឌដង្កោ បានឲ្យដឹងថា នរណាៗក៏ពេញចិត្តនឹងការងារដោះស្រាយបញ្ហាព្រំដែន របស់គណបក្សទាំងពីរមែនទែន ហើយសង្ឃឹមថា បើគណបក្សទាំងពីរ បន្តធ្វើការដោយភាពស៊ីសង្វាក់គ្នា ដូចដែលបានធ្វើ កាលពីដើមខែកក្កដា គឺថាទាំងលោក និងប្រជាពលរដ្ឋឯទៀត គឺមានជំនឿថា យើងនឹងអាចដោះស្រាយបាន រឿងព្រំដែននេះដោយសុក្រិតភាព និងទទួលយកបាន ប៉ុន្តែស្ថានភាព នៅចុងខែកក្កដា លោកហាក់ដូចជារៀងអស់ជំនឿបន្តិចវិញ ។

លោកបានបញ្ជាក់ថា "កាលពីដើមខែកក្កដា ទាំងខ្ញុំទាំងគេ នរណាក៏ពេញចិត្តនឹងការងារ គណបក្សទាំងពីរដែរ តែដល់ចុងខែដូចជាអស់សង្ឃឹមវិញ"។

លោកបានបន្តថា លោកមិនយល់ដែរនឹងស្ថានការណ៍ចុងក្រោយ នៃការវិវត្តន៍នយោបាយនៅកម្ពុជា កាលពីចុងខែកក្កដា ខណៈដែល កាលពីដើមខែសភាពការណ៍ហាក់ដូចជាល្អកល្អើននឹងគ្នា ។

ព្រឹត្តិការណ៍ដែល ប្រជាពលរដ្ឋបង្ហាញពីការរីករាយ និងជំនឿចិត្តទៅលើគណបក្សទាំងពីរ ដែលបានធ្វើនៅក្នុងខែកក្កដា គឺរឿងស្មារតីនៃការដោះស្រាយបញ្ហាព្រំដែនតាមតួនាទី និងភារៈកិច្ច របស់អ្នកនយោបាយ និងមន្ត្រីប្រតិបិត្តការណ៍ការងារ ក៏ដូចជាភាពល្អកល្អើន នៃប្រមុខដឹកនាំគណបក្សទាំងពីរ នៅក្នុងពិធីទទួលទានអាហារពេលល្ងាចរួមគ្នា រវាងក្រុមគ្រួសារលោក សម រង្ស៊ី និងក្រុមគ្រួសារសម្តេចតេជោ ហ៊ុន សែន ប៉ុន្តែសភាពការណ៍បានហាក់ប្រែប្រួល ក្រោយពេលលោក សម រង្ស៊ី បានបញ្ចេញសកម្មភាពបែបចំអកដល់រាជរដ្ឋាភិបាលកម្ពុជា ដែលដឹកនាំដោយគណបក្ស ប្រជាជនកម្ពុជា អំពីបញ្ហាផែនទី ហើយនិងការដែលអាជ្ញាធរកម្ពុជា បានកោះហៅសកម្មជនគណបក្សសង្គ្រោះជាតិ ១១នាក់ ដោយរួមទាំងលោក មៀច សុវណ្ណារ៉ា ប្រធាននាយកដ្ឋានព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយគណបក្សសង្គ្រោះជាតិ និងជាអនុប្រធានក្រុមការងារខេត្តបន្ទាយមានជ័យ ក្រោមបទចោទប្រកាន់ ពីបទករណីហិង្សានៅទីលានប្រជាធិបតេយ្យ កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៤កន្លងទៅហើយកាត់ទោសដាក់ពន្ធនាគារពី ៧ ទៅ២០ឆ្នាំ។

លោក រចនា បានបញ្ជាក់ថា "គណបក្សទាំងពីរ មិនគួរមានអរិយភាពនឹងគ្នាទេ គួរតែបន្តធ្វើការរួមគ្នា ដោយសុទិដ្ឋិនិយម តាមតួនាទីស្របតាមច្បាប់ "។

ជុំវិញបញ្ហាព្រំដែន នេះលោក ឈឹម ផលវុណ្ណ អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជាបានមានប្រសាសន៍ថា រឿងបញ្ហាព្រំដែន គឺជារឿងដែលគណបក្សប្រជាជនកម្ពុជា ដែលជាគណបក្សកាន់អំណាច បានខិតខំធ្វើជាបន្តបន្ទាប់ ហើយមិនមែនទើបតែធ្វើនោះទេ តែ

## កម្ពុជាមាន៥លានដុល្លារ ដើម្បីផ្ទៀងផ្ទាត់ផែនទី

សម្តេច ហ៊ុន សែន បានប្រកាសបើកចំហ ឲ្យមានតំណាងស្ថាប័នជាតិ តំណាងគណបក្សនយោបាយ និង តំណាងអង្គការសង្គមស៊ីវិល ជិះយន្តហោះទៅត្រួតពិនិត្យផែនទីកម្ពុជា ដល់ទីស្នាក់ការ អង្គការសហប្រជាជាតិ នៅប្រទេសបារាំង នៅអង់គ្លេស និងនៅអាមេរិក។

មានប្រសាសន៍ នៅក្នុងពិធីសម្ពោធស្ពានមិត្តភាព កម្ពុជា - ចិន (តាខ្មៅ) សម្តេចហ៊ុន សែន បានមានប្រសាសន៍ថាកិច្ចការនេះគឺរដ្ឋាភិបាលអាចចំណាយត្រឹមតែ៥លានដុល្លារប៉ុណ្ណោះ។

សម្តេចបានបន្ថែមថា តំណាងគណបក្សនយោបាយក្រៅរដ្ឋាភិបាល នៅរដ្ឋសភា នៅព្រឹទ្ធសភា និងគណបក្សនយោបាយនានា តំណាងស្ថាប័នជាតិ រួមមាន ក្រុមប្រឹក្សាធម្មនុញ្ញ និងឧត្តមក្រុមប្រឹក្សាអង្គចៅក្រមជាដើម ត្រូវបញ្ជូនតំណាង ២រូបៗ ដើម្បីទៅត្រួតពិនិត្យផ្ទៀងផ្ទាត់ផែនទីកម្ពុជា នៅអង្គការសហប្រជាជាតិ នាប្រទេសអាមេរិក បារាំង និងអង់គ្លេស។

# តដោះស្រាយតែត្រូវតែទាមទារការរួបរួមគ្នា



ការី

គណបក្សប្រឆាំងទេ ដែលចេះតែយករឿងនោះមកនិយាយបំប៉ោង ។

លោកបានបញ្ជាក់ថា "បើគណបក្សប្រជាជនកម្ពុជា មិនយកចិត្តទុកដាក់ មិនមែនយើង បានបោះបង្គោលព្រំដែនបានរហូតដល់ទៅ ៨៣ភាគរយដែរ "។

លោកបានបន្តថា ជុំវិញបញ្ហាដែលខាងគណបក្សប្រឆាំង តែងតែចោទរដ្ឋាភិបាល ដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា ជាអាយ៉ងរបស់វៀតណាមនោះ គឺជារឿងចោទប្រកាន់គ្មានមូលដ្ឋាន។

លោកបានបញ្ជាក់ថា "បើសិនជាគណបក្សប្រជាជនកម្ពុជា អាយ៉ងគេនោះ (វៀតណាម)ឲ្យយើងដេកៗ ឈរ គឺឈរហើយ មិនមែនទុកឲ្យវានេះមានបញ្ហាដូចជាបច្ចុប្បន្ននេះទេ"។

លោកបានបន្តទៀតថា កិច្ចការដោះស្រាយបញ្ហាព្រំដែននេះ គឺមិនមែនជារឿងដែល ងាយដោះស្រាយនោះទេ។ វាគឺជារឿងដែលស្មុគស្មាញ ទាមទារពេលវេលា ទាមទារការជជែកគ្នាច្រើនជាអន្តរជាតិ។ ជាបទពិសោធន៍រឿងដោះស្រាយបញ្ហាព្រំដែននេះ ដើម្បីកុំឲ្យវាមានទំនាស់ គឺថាកន្លែងដែលដោះស្រាយមិនចេញ គឺទុកឲ្យស្ថានការណ៍នៅដែល។

ទាក់ទងនឹងបញ្ហា ព្រំដែននេះដែរ សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជានៅក្នុងពិធីសម្ពោធស្ពានមិត្តភាព កម្ពុជា-ចិនតាខ្មៅ កាលពីថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៥ បានមានប្រសាសន៍ថា រឿងចោទប្រកាន់ផ្សេងៗមកលើរូបសម្តេច និងគណបក្សប្រជាជនកម្ពុជា អំពីការដោះស្រាយបញ្ហាព្រំដែន ជាមួយនឹងប្រទេសវៀតណាមគឺជារឿងអយុត្តិធម៌សម្រាប់លោក និងគណបក្សប្រជាជនកម្ពុជា ហើយក៏ជារឿងមួយ ដែលមិនអាចទទួលយកបាន។

ជាមួយគ្នានោះ សម្តេចនាយករដ្ឋមន្ត្រីក៏បានអំពាវនាវ ដល់អ្នកនយោបាយដែលបានជំរុញឲ្យរដ្ឋាភិបាលកម្ពុជា ប្តឹងវៀតណាម ទៅតុលាការយុត្តិធម៌អន្តរជាតិ គួរតែធ្វើសារណា បញ្ជាក់មកកាន់រដ្ឋាភិបាលថា តើប្តឹងចំណុចណា? ធ្វើដូចម្តេច? កន្លែងណាជាចំណុចខ្លាំង ព្រោះបើតាមសម្តេច គឺកម្ពុជាមិនអាចប្តឹងវៀតណាមរឿងព្រំដែន ទៅកាន់តុលាការយុត្តិធម៌អន្តរជាតិបាននោះទេ។

សម្តេចតេជោ ហ៊ុន សែន ក៏បានថ្លែងបញ្ជាក់ អំពីជំហររបស់គណបក្សប្រជាជនកម្ពុជា និងរាជរដ្ឋាភិបាល នៅក្នុងការបន្តការពារ បូរណភាពដែនដី ស្របតាមរដ្ឋធម្មនុញ្ញ និងច្បាប់ដែលមានដើម្បីជាប្រយោជន៍សម្រាប់ជាតិ និងមាតុភូមិ ។

សម្តេចតេជោ ហ៊ុន សែន ក៏បានប្រកាស នូវកញ្ចប់ថវិកាមួយកញ្ចប់សម្រាប់នាំតំណាងគណបក្សនយោបាយ សង្គមស៊ីវិល មន្ត្រីរដ្ឋាភិបាល ទៅផ្ទៀតផ្ទាត់ផែនទីនៅអាមេរិក បារាំង និងអង់គ្លេស។

ឆ្លើយតបនឹងបញ្ហាព្រំដែននេះ លោក អ៊ុំ សំអាន តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ បានមានប្រសាសន៍ប្រាប់អ្នកសារព័ត៌មានថា លោកត្រៀមខ្លួនគ្រប់ពេលវេលា ដើម្បីធ្វើការផ្ទៀតផ្ទាត់ផែនទី។ លោកបានបន្តថា បើសិនជាកុំឲ្យទាស់គ្នា លើបញ្ហាផែនទីនេះ គឺដំណោះស្រាយ មានតែយកផែនទី ពីអង្គការសហប្រជាជាតិ មកផ្ទៀងផ្ទាត់ប៉ុណ្ណោះ។

ជុំវិញបញ្ហាទាំងអស់នេះ ប្រជាពលរដ្ឋកម្ពុជា បានជំរុញ និងស្នើសុំឲ្យគណបក្សទាំងពីរ ដែលមានអសនៈនៅក្នុងសភាទាំងពីរ បន្តគោលជំហរប្រកាន់យកវប្បធម៌សន្ទនា ដែលបានអនុវត្ត និងប្រកាន់យក រវាងប្រមុខគណបក្សនយោបាយទាំងពីរឡើងវិញ។

លោក រចនា បានឲ្យដឹងថា ឥឡូវនេះ មិនទាន់ដល់ពេលបោះឆ្នោតទេ នៅក្នុងនាមខ្ញុំជាពលរដ្ឋ សូមឲ្យគណបក្សទាំងពីរបន្តវប្បធម៌សន្ទនាឡើងវិញ។

លោកបានបញ្ជាក់ថា "កុំអាលពាក់មុខយក្សដាក់គ្នាអី ព្រោះពេលវេលា វានៅឆ្ងាយគួរសមដែរ ទម្រាំដល់ការបោះឆ្នោតលើកក្រោយ"។

លោក ច័ន្ទតារា "បើចាំបាន គួរចាំគៀកការបោះឆ្នោត ចាំឈ្លោះគ្នាទើបប្រសើរ ឥឡូវនេះ គួរតែអង្គុយដោះស្រាយបញ្ហាគ្នា ដោយវប្បធម៌សន្ទនានេះ ប្រហែលជាជាតិអាចដោះស្រាយបញ្ហាអសកម្មបានច្រើន"៕

*ដោយអរិយបុត្រ*

## អគ្គលេខាធិការអង្គការប្រជាជាតិ ឆ្លើយតបនឹងសំណើរកម្ពុជា

កាលពីថ្ងៃទី០៥ ខែសីហា ឆ្នាំ ២០១៥ លោកបាន គីមូន អគ្គលេខាធិការអង្គការសហប្រជាជាតិ បានឆ្លើយតប ប្រកបដោយភាពវិជ្ជមាន ចំពោះសំណើរ សម្តេច តេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ។

លោក បាន គីមូន បានជម្រាបសម្តេចតេជោថា ផែនទីកម្ពុជា ដែលផលិតឡើងនៅចន្លោះឆ្នាំ ១៩៣៣ ដល់ឆ្នាំ១៩៥៣អង្គការសហប្រជាជាតិរកមិនឃើញទេ ប៉ុន្តែមានផែនទីដើមរបស់កម្ពុជាមួយចំនួន ដែលអង្គការសហប្រជាជាតិរកឃើញ និងយល់ព្រមឲ្យកម្ពុជាខ្ចី។

លោកបានបញ្ជាក់ថា អ.ស.ប បានផ្តល់នូវផែនទីមួយឈុត ជាទម្រង់ឌីជីតាល់ ដល់លោក ទុយ រី តំណាងអចិន្ត្រៃយ៍របស់កម្ពុជា ប្រចាំអង្គការសហប្រជាជាតិ នៅថ្ងៃទី២៧ ខែកក្កដា ហើយ ក៏ព្រមព្រៀងឲ្យកម្ពុជាខ្ចីផែនទីជាក្រដាសមួយរយៈពេល តាមកិច្ចព្រមព្រៀងមួយដាក់លាក់។

បន្ទាប់ពីទទួលចម្លើយ ជាវិជ្ជមាននេះ សម្តេចតេជោ ហ៊ុន សែន នៅថ្ងៃទី៦ ខែសីហា បានចុះហត្ថលេខាលើសេចក្តីសម្រេចស្តីពី ការបង្កើតគណៈ-កម្មការចំពោះកិច្ច សម្រាប់សម្របសម្រួលការងារទទួលប្រគល់ និងផ្ទៀងផ្ទាត់ផែនទីនេះភ្លាម ។

គណៈកម្មការនោះ មានសមាសភាពចំនួន ១១ រូប ដែលដឹកនាំដោយលោក ហោ ណាំហុង ឧបនាយករដ្ឋ-មន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេសជាប្រធាន លោក វ៉ា គឹមហុង ទេសរដ្ឋ-មន្ត្រីទទួលបន្ទុកកិច្ចការព្រំដែន និង លោក អ៊ឹម ឈុនលឹម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំ ដែនដីនគរូបនីយកម្ម និងសំណង់ជាអនុប្រធាន ។

# និស្សិតសន្តយ៉ូស្ទីនធ្វើទស្សនកិច្ចនៅប្រទេសហ្វីលីពីន







និស្សិតនៃសាលាអប់រំជំនឿ សន្ត យ៉ូស្ទីន

និស្សិតនៃសាលាអប់រំជំនឿ សន្ត យ៉ូស្ទីន (St. Justine School of Faith) ចំនួន៥០នាក់ បានរៀបចំកម្មវិធីដំណើរទស្សនកិច្ចសិក្សាទៅប្រទេសហ្វីលីពីន ដើម្បីស្វែងយល់អំពីជំនឿ និងរបៀបរស់នៅរបស់ប្រជាជនក្នុងប្រទេសនោះ ដែលភាគច្រើនជាគ្រីស្តបរិស័ទកាតូលិក។

សាលាអប់រំជំនឿសន្តយ៉ូស្ទីន ជាសាលាមួយ ដែលបណ្តុះបណ្តាលគ្រីស្តបរិស័ទកាតូលិករយៈពេលពីរឆ្នាំ អំពីជំនឿព្រះគម្ពីរ របៀបរស់នៅតាមជំនឿនៅក្នុងសង្គម និង ការប្រតិបត្តិជំនឿរបស់ខ្លួនដោយបម្រើអ្នកដទៃក្នុងសង្គម ដើម្បីប្រកាសដំណឹងល្អ របស់ព្រះជាម្ចាស់។

ដំណើរទស្សនកិច្ចនេះ បានធ្វើឡើងចំនួនមួយសប្តាហ៍ ចាប់ពីថ្ងៃទី២៤ ដល់៣១កក្កដា ក្រោមការដឹកនាំរបស់លោកអភិបាល ជ្ញីតអឺស្លៃ អូលីវីយេ រួមនិងលោកបូជាចារ្យសេន័យឆាល់ វ៉ាំងសង់។

លោកអភិបាល អូលីវីយេ ដោអភិបាលព្រះសហគមន៍កាតូលិក ភូមិភាគភ្នំពេញ និងជានាយក នៃសាលាអប់រំជំនឿសន្តយ៉ូស្ទីន បានមានប្រសាសន៍ថា ដំណើរទស្សនកិច្ចទៅប្រទេសហ្វីលីពីននេះ គឺដើម្បីឲ្យនិស្សិតទាំងអស់មានឱកាស ទទួលបទពិសោធន៍អំពីជំនឿ និងការប្រតិបត្តិជំនឿពីប្រទេសនេះ។ លោកអភិបាលបន្ថែមថា ក្នុងដំណើរទស្សនកិច្ចនេះ ក្រុមនិស្សិតសាលាសន្តយ៉ូស្ទីន បានទៅទស្សនា និងសិក្សាកន្លែងព្រះសហគមន៍ផ្សេងៗ ក្នុងប្រទេសហ្វីលីពីន ទាំងកន្លែងអ្នកមាននិងកន្លែងក្រីក្រដើម្បីឲ្យនិស្សិតកាន់តែមានគំនិតទូលំទូលាយ ក្នុងការចូលរួមកសាងព្រះសហគមន៍កាតូលិក នៅប្រទេសកម្ពុជាវិញ។

លោកផុន សុផល ជាអ្នករៀបចំកម្មវិធីនៃដំណើរទស្សនកិច្ចសិក្សានេះ បានឲ្យដឹងថា៖ "កម្មវិធីទស្សនកិច្ចនេះ ធ្វើឡើង គឺចង់ឲ្យនិស្សិត បានមើលឃើញ និងបានសិក្សាអំពីជំនឿការរស់នៅ ការទំនាក់ទំនង ស្ថានភាពទូទៅ និងការទទួលស្វាគមន៍របស់ គ្រីសបរិស័ទនៅប្រទេសហ្វីលីពីន"។

លោកសុផល បានបន្ថែមទៀតថា ដំណើរទស្សនកិច្ចនេះ ក៏អាចណែនាំឲ្យនិស្សិតយល់ដឹងពីជំនឿបន្ថែម និងឲ្យជំនឿពួកគាត់រីកចំរើន ដោយយោងតាមបទពិសោធន៍ នៃគ្រីស្តបរិស័ទប្រទេសហ្វីលីពីន។ ម្យ៉ាងវិញទៀត ពួកគាត់នឹងមានគំនិងច្នៃប្រឌិតជាច្រើន ដើម្បីធ្វើជាគ្រូអប់រំជំនឿ និង បង្កើតសកម្មភាពផ្សេងទៀតនៅពេលទៅដល់ ប្រទេសកម្ពុជាវិញ។

អ្នកស្រី គឹម សារ៉ន ជានិស្សិតជំនាន់ទី២ នៃសាលាសន្តយ៉ូស្ទីន បានឲ្យដឹងដែរថា នេះជាលើកទី១ ដែលអ្នកស្រីបានមកដល់ប្រទេសហ្វីលីពីន។អ្នកស្រីបានបន្ថែមថា ឆ្លងតាមការដើរទៅកន្លែងផ្សេងៗជាច្រើន ក្នុងប្រទេសនេះ អ្នកស្រីបានទទួលបទពិសោធន៍ ជាច្រើនផងដែរ ដូចជាអំពីរបៀបនៃការចុះធ្វើការងារសហគមន៍ ការប្រកាសដំណឹងល្អ និងការរួបរួមគ្នាជាសហគមន៍គ្រីស្តបរិស័ទ។

លើសពីនេះ អ្នកស្រីបន្ថែមទៀតថា នៅពេលដែលអ្នកស្រី វិលត្រឡប់មកប្រទេសកម្ពុជា អ្នកស្រីនឹងចែករំលែក បទពិសោធមន៍ ដែលមានក្នុងព្រះសហគមន៍ នៅប្រទេសហ្វីលីពីននេះ ទៅដល់បងប្អូន គ្រីស្តបរិស័ទឯទៀតៗ ឲ្យបានដឹង ជាពិសេសអំពីរបៀបដែលគ្រីស្តបរិស័ទហ្វីលីពីន លះបង់កម្លាំងកាយចិត្តដើម្បីជួយគ្នាទៅវិញទៅមក។

ដំណើរទស្សនកិច្ចសិក្សានេះ បានធ្វើឡើងរយៈ៧ថ្ងៃ ដោយបានទៅកាន់ព្រះវិហារជាច្រើននៅក្នុងតំបន់ម៉ានីឡា ទីលានចាក់សំរាម តំបន់កសិដ្ឋានសម្រាប់សហគមន៍ អាសនៈវិហារសន្តសិលា និងអាសនៈវិហារអាន់ទីប៉ូឡូ កន្លែង ផលិតកម្មវិធីវិទ្យុវ៉ារីតាសអាស៊ីសហគមន៍ហ្វាន់ដាហ្ស មណ្ឌល អភិវឌ្ឍយុវជន ជំនួបជាមួយលោកកាឌីណាល់តាកលេ និងការិយាល័យ សម្រាប់យុវជនប្រទេសហ្វីលីពីនទាំងមូល។

សាលាសន្តយ៉ូស្ទីន បានបង្កើតឡើងក្នុងឆ្នាំ២០១២ សម្រាប់អប់រំគ្រីស្តបរិស័ទក្នុងព្រះសហគមន៍កាតូលិក ភូមិភាគភ្នំពេញ ដែលមានរយៈពេលសិក្សាចំនួន២ឆ្នាំ។ ក្នុងឆ្នាំសិក្សានីមួយៗ និស្សិតនៃសាលានេះបានចុះទស្សនកិច្ចសិក្សាតាមប្រទេសនានា ដើម្បីទទួលបានបទពិសោធន៍ថ្មីៗ ក្នុងការកសាងព្រះសហគមន៍ នៅតាមតំបន់របស់ខ្លួន ដែលមានដូចជាប្រទេស ថៃ ឡាវ វៀតណាម អ៊ីស្រាអែល និងហ្វីលីពីនជាដើម។

*ដោយរឿន ស្រីម៉ាច*

# កាន់ ប៊ុយ ៖

## ជីវិតក្មេងកំព្រាឈប់ពឹងលើខ្លួនឯងតែពឹងលើព្រះជាម្ចាស់



កាន់ ប៊ុយ ជាឈ្មោះយុវជនម្នាក់រស់នៅដោយប្រើជីវិតផ្សងព្រេង តាំងពីបាត់បង់ឪពុកម្ដាយក្នុងវ័យជំទង់។ គាត់ធ្លាប់ជួបប្រទះទុក្ខសោក នៃការបាត់បង់សាច់ញាតិ ការសិក្សា និងកំលាំងចិត្ត។ ភាពអស់សង្ឃឹមបាននាំជីវិតរបស់គេឲ្យតែលតោលគ្មានទិសដៅ។ តែគាត់បានមកប្រសព្វនឹង ព្រះសហគមន៍កាតូលិក ដែលជាទីដែលគាត់ធ្លាប់ បានប្រឆាំង និងរិះគន់ មុនពេលផ្លាស់ប្ដូរជំនឿរបស់ខ្លួនជាកាតូលិក។

កាន់ ប៊ុយ ដែលបច្ចុប្បន្នកំពុងសិក្សាផ្នែកគម្ពីរវិទ្យាគ្រីស្ដសាសនា នៅប្រទេសបារាំងបានចំនួន២ឆ្នាំបាន និយាយថា "បើគ្មានការព្រាត់ប្រាស់ ឪពុកម្ដាយ ក៏មិនអាចរកឃើញ ព្រះជាម្ចាស់ដែលជាប្រភពនៃសេចក្ដីស្រឡាញ់ដែរ"។

កាន់ ប៊ុយ បានទៅសិក្សាបន្តជំនាញគម្ពីរនេះនៅបារាំង ព្រោះគាត់ចង់បំពេញបន្ថែមភាពខ្វះខាតខាងធនធានមនុស្សរបស់ព្រះសហគមន៍កាតូលិកអំពីគម្ពីរ។

កាន់ ប៊ុយ "ខ្ញុំគិតថា គម្ពីរមានសារៈសំខាន់ណាស់។ ការសិក្សានេះ ខ្ញុំនឹងអាចក្លាយជាចំណែកមួយក្នុងការចែករំលែកពិសោធននៃជំនឿដល់បងប្អូនគ្រីស្ដបរិស័ទនៅកម្ពុជាបាន ព្រោះគម្ពីរជាគ្រឹះនៃអ្វីៗទាំងអស់របស់គ្រីស្ដបរិស័ទ"។

ក្នុងពេលវិស្សមកាលឆ្នាំនេះ លោកសិលាកាន់ប៊ុយបានមកប្រទេសកំណើតដើម្បីចែករំលែកបទពិសោធន៍ ជំនឿរបស់ខ្លួនដល់គ្រីស្ដបរិស័ទ និង យុវជនឯទៀតដើម្បីឲ្យគេស្រឡាញ់ព្រះជាម្ចាស់ដោយស្រឡាញ់ព្រះបន្ទូលរបស់ព្រះអង្គ និងមិនអស់សង្ឃឹមក្នុងជីវិត។

សិលា កាន់ ប៊ុយ ជាឈ្មោះថ្មី ពេលលោកទទួលអគ្គសញ្ញាជ្រមុជទឹក ជាគ្រីស្ដបរិស័ទកាតូលិកក្នុងឆ្នាំ២០០៦។ លោកបានជ្រើសរើសឧបការីឈ្មោះសិលាព្រោះគាត់ជាអ្នកនេសាទត្រីដូចគ្នា។

មើលរូបរាងពីខាងក្រៅ គ្មាននរណាដឹងថា យុវជនអាយុ៣១ឆ្នាំរូបនេះ ធ្លាប់ជាអ្នកនេសាទត្រី ឬជាកសិករដែលធ្វើការបែកញើសហូរញើសពីមុនមកទេ ។ និយាយដោយលាដៃទាំងពីរបង្ហាញផង ប៊ុយប្រាប់ទៀតថា គាត់ធ្លាប់ធ្វើការទាំងអស់នោះតាំងពីតូចមក ហើយក៏ធ្លាប់ឈប់រៀនជាច្រើនសារមកដែរ ព្រោះតែជីវភាពគ្រួសារ និងស្ថានភាពកំព្រា។

ប៊ុយ ជាមនុស្សដែលស្ងាត់ស្ងៀមនិងមិនសូវនិយាយស្ដីច្រើនទេ តែមនុស្សជាច្រើនចូលចិត្តគាត់។ភាពសោះកក្រោះនេះ ប្រហែលជាមកពីការរងទុក្ខ ដោយការបាត់បង់ភាពកក់ក្ដៅ ក្នុងជីវិតក៏ថាបាន ព្រោះម្ដាយរបស់គាត់ បានស្លាប់ពេលគាត់អាយុបានតែ ៩ឆ្នាំប៉ុណ្ណោះ ហើយឪពុកក៏ស្លាប់ទៀត ពេលគាត់អាយុ១៦ឆ្នាំ។ ការស្លាប់របស់ពួកគាត់បានធ្វើឲ្យចិត្តរបស់ ប៊ុយ រងរបួស ដោយប្រើជីវិតផ្សងព្រេង ខ្លួនទីពឹងខ្លួនគ្រប់ទីកន្លែង ដើម្បីស្វែងរកការសិក្សា តាមបណ្ដាំចុងក្រោយរបស់ឪពុកខ្លួន។

ប៊ុយបានរំឭកថា "ឪពុកខ្ញុំបានប្រាប់ពាក្យចុងក្រោយ គឺបើកូនមិនតស៊ូព្យាយាមរៀនសូត្រទេ នោះអនាគតកូនមានតែតោងកន្ទុយនង្គ័ល ធ្វើការកណ្ដាលវាលស្រែ ចម្ការក្រោមកំដៅថ្ងៃ ក្រោមភ្លៀង... ហើយវាសនាចុងក្រោយ នឹងធ្លាក់ខ្លួនទៅជាខ្ញុំគេដូចពុកអញ្ចឹង"។

ក្នុងសៀវភៅ ដែលមានចំណងជើងថា ជំនឿរបស់ខ្ញុំ ដែលសរសេរដោយប៊ុយផ្ទាល់បានបញ្ជាក់ថា ប្រសិនបើគ្មានពាក្យសំដីឪពុកនេះទេ ប្រហែលជាគាត់អាចនឹងក្លាយជាក្មេងពាល ឬមនុស្សគ្មានបានការសម្រាប់សង្គមទៅហើយ។

រំឭកពីជីវិតអនាថា សិលា កាន់ ប៊ុយ ដែលមកពី គ្រួសារកសិករពុទ្ធបរិស័ទ ប្រាប់ថា គាត់ចេះធម៌ព្រះពុទ្ធ យ៉ាងស្ទាត់ផងដែរ ព្រោះគាត់ក៏ធ្លាប់ បានបួសជាសាមណេមួយរយៈ ហើយក៏ធ្លាប់រស់នៅក្នុងវត្តអារាមដើម្បីបន្តរៀននៅវិទ្យាល័យ ព្រោះក្រោយពីលោកពូ របស់គាត់ទទួលអនិច្ចកម្ម គាត់គ្មានទីពឹងទៀតឡើយ។ តាំងពីតូចដល់ធំ គាត់លឺពាក្យមិនល្អជាច្រើនរបស់អ្នកដទៃ អំពីគ្រីស្ដសាសនា ហើយរូបគាត់ ក៏គិតដូចគេដែរ ថែមទាំងធ្លាប់ចំអកឡកឡឺយ ដល់មិត្តរួមថ្នាក់ អំពីជំនឿរបស់គេ ទាំងមិនដឹងថាអ្វីទៅជាគ្រីស្ដសាសនានៅឡើយ។

ក្រោយមកគំនិតនេះ ត្រូវបានផ្លាស់ប្ដូរទាំងស្រុង បន្ទាប់ពីបានស្គាល់ធម៌មេត្តាករុណារបស់ព្រះសហគមន៍ចំពោះអ្នកក្រីក្រ។ គាត់បានសុំលោកបូជាចារ្យដើម្បីរៀនអប់រំជំនឿជាគ្រីស្ដបរិស័ទ ។ កាន់ ប៊ុយ "ក្រោយពីខ្ញុំបានទទួលការអប់រំជំនឿ ជីវិតរបស់ខ្ញុំដូចជារស់ជាថ្មីម្យ៉ាងព្រោះវាជាបទពិសោធន៍ នៃជីវិតម្យ៉ាងដែលខ្ញុំធ្លាប់ឯកោ ធ្លាប់ស្ងៀមស្ងាត់ និង បាត់បង់គ្រួសារ ជាជីវិតដែលកំពុងស្វែងរកអត្ថន័យ តើវាជាអ្វី? ខ្ញុំស្វែងរកតាមព្រះពុទ្ធសាសនា ហើយក្រោយពេលខ្ញុំទទួលអប់រំជំនឿ ខ្ញុំឃើញថាមាគ៌ាទាំងពីប្លែកពីគ្នា។ ហើយខ្ញុំបានរកឃើញអំណរវិញនៅក្នុងគ្រីស្ដសាសនា។ ជីវិតជាក្មេងកំព្រា កាលណាឮពាក្យថាព្រះជាម្ចាស់ជាព្រះបិតា ជាអ្វីមួយជួយជំរុញទឹកចិត្តរបស់ខ្ញុំថាខ្ញុំលែងកំព្រា"។

រឿងរ៉ាវកន្លងមកនេះ ប៊ុយ បានចាត់ទុកជាមេរៀនជីវិតមួយដែលខ្លួនត្រូវចេះត្រៀមខ្លួន និងទទួលស្គាល់ការពិតរបស់ខ្លួន។ បើនិយាយពីសង្គម អ្នកនៅតែតូចចិត្តនឹងភាពអយុត្តិធម៌ និងការគាបសង្កត់របស់អ្នកមានអំណាច។ តែជាមួយគ្នានេះ កាន់ ប៊ុយ លែងពឹងលើខ្លួនឯងទៀតហើយគឺពឹងលើធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ជំនួសវិញ ។ សិលា កាន់ ប៊ុយ "ខ្ញុំលែងជាម្ចាស់លើខ្លួនឯងតែព្រះជាម្ចាស់ជាអ្នកតម្រង់ទិសខ្ញុំ"៕

*ដោយកល្យប្រឹក្ស*

---

# សន្តលូកា

លោកលូកា កើតនៅក្រុង អង់ទីយ៉ូក។ លោកជាជនជាតិក្រិក។ លោកពូកែខាងនិពន្ធរឿង គូររូប មិនតែប៉ុណ្ណោះ លោកជាគ្រូពេទ្យផង ជាពិសេស គាត់ចូលចិត្តស្ដាប់គេ និងរិះគិតពិចារណា។ ថ្ងៃមួយគាត់ស្ដាប់គ្រីស្ដបរិស័ទម្នាក់ កំពុងនិយាយអំពីព្រះយេស៊ូនៅទីប្រជុំជន។ គាត់ក៏ធ្លាប់ឃើញគ្រីស្ដបរិស័ទ អធិដ្ឋានលើកលែងទោសគ្នាទៅវិញទៅមក ឃើញអ្នកមាននិងអ្នកក្រមិនប្រកាន់គ្នា រាប់អានគ្នាដូចបងប្អូនបង្កើត។ ពួកគេហាក់ដូចជាពន្លឺមួយដែលបំភ្លឺអ្នកដទៃ។

លោកលូកា ក៏ចង់ស្គាល់ព្រះយេស៊ូដែរ។ គាត់ទៅជួបលោសិលា និងលោកប៉ូល ដែលតែងតែប្រកាសថា លោកយេស៊ូ ដែលគេឆ្កាងសម្លាប់នោះ ឥឡូវមានជីវិតថ្មី ហើយលោកទាំងពីរក៏ធ្លាប់នៅ និងដើរតាមលោកយេស៊ូនោះដែរ។ យូរៗទៅលោកលូកាក៏ក្លាយជាមិត្តជិតស្និទ្ធរបស់លោកប៉ូល ហើយដើរតាមលោក ដើម្បីប្រកាសដំណឹងល្អ។ លោកក៏បានកត់ត្រាកិច្ចការទាំងឡាយដែលក្រុមសាវ័ក របស់ព្រះយេស៊ូបានធ្វើ។ សៀវភៅនោះ លោកដាក់ឈ្មោះថា "កិច្ចការគ្រីស្ដទូត"។

ក្រោយមកលោកក៏បាននិពន្ធសៀវភៅមួយក្បាលទៀត ដើម្បីសម្ដែងជំនឿលើព្រះយេស៊ូ ដោយលោកបានប្រមូលសេចក្ដីជាច្រើនដែលលោកសិលា លោកយ៉ូហាន លោកអន់ ជ្រេ លោកម៉ាថាយ បានសរសេរ ព្រោះលោកទាំងនោះ ជាសាវ័ក ដែលធ្លាប់រស់នៅជាមួយព្រះយេស៊ូអស់ជាច្រើនឆ្នាំ។ សៀវភៅនោះរៀបរាប់អំពីព្រះយេស៊ូប្រសូត តាមរបៀបសម្ពន្ធមេត្រីចាស់ អំពីនាងម៉ារី និងនាងអេលីសាបិត អំពីកិច្ចការមួយចំនួនរបស់ព្រះយេស៊ូ និងការសោយទិវង្គតរបស់ព្រះអង្គ។ ប៉ុន្តែមុននឹងតាក់តែងសៀវនេះបាន លោកលូកាបានសម្រេចចិត្តរកពេលវេលា ដើម្បីអធិដ្ឋានស្ដាប់ព្រះបន្ទូលព្រះអង្គសិន ដោយរស់នៅដាច់ឡែកពីគេ។ "មនុស្សជាច្រើនខិតខំយកចិត្តទុកដាក់កត់ត្រាទុក នូវហេតុការណ៍ទាំងអស់ ដែលកើតមានក្នុងចំណោមយើង។ អស់អ្នកដែលបាន



ឃើញផ្ទាល់នឹងភ្នែក បានរៀបរាប់ហេតុការណ៍ទាំងនោះ។ ខ្ញុំបានពិនិត្យហេតុការណ៍នោះយ៉ាងហ្មត់ចត់ ហើយខ្ញុំក៏យល់ឃើញថា គួរតែកត់ត្រាទុកក្នុងគោលបំណង ចង់ឲ្យមិត្តអ្នកអានជ្រាបដែរ"។ (*លក ១.១-៤*)

# ព្រះសហគមន៍ប៉ោយប៉ែត រំឭកសន្តីម៉ារីម៉ាដាឡា ជាឧបការី



*គ្រីស្តបរិស័ទជួបជុំគ្នាដើម្បីរំឭកសន្តីម៉ារីម៉ាដាឡាជាឧបការី។ សុភាព*

ក្រុមគ្រីស្តបរិស័ទ ប្រមាណជាង ២០០នាក់ បានរួមគ្នាដង្ហែរូបសំណាក សន្តីម៉ារីម៉ាដាឡា ដែលជាឧបការី នៃព្រះវិហាររបស់ខ្លួន ចូលក្នុងព្រះវិហារជាការរំឭកអំពីជំនឿ ដែលសន្តីរូបនេះបានធ្វើ។ ពិធីនេះបានធ្វើឡើង កាលពីថ្ងៃទី២៦ ខែកក្កដាកន្លងទៅ នៅព្រះវិហារសន្តីម៉ារីម៉ាដាឡា នៃព្រះសហគមន៍កាតូលិកប៉ោយប៉ែត ក្រោមអធិបតីភាព លោកបូជាចារ្យឡាមុង កាព្រីអែល ឡង់ (ហ្គាប៊ី)។

លោកសេង សុភាព ជាប្រធានគណកម្មការព្រះវិហារសន្តីម៉ារីម៉ាដាឡា នៃព្រះសហគមន៍កាតូលិក ប៉ោយប៉ែត បានឲ្យដឹងថាព្រះសហគមន៍ប៉ោយប៉ែត បានជ្រើសរើស សន្តីម៉ារីម៉ាដាឡា ជាឧបការី នៃព្រះសហគមន៍របស់ខ្លួន ដោយចាត់ទុកសន្តីម៉ារីម៉ាដាឡា ជាគំរូនៃជំនឿរបស់គ្រីស្តបរិស័ទ នៅទីនេះ ព្រោះកាលពីមុន ព្រះសហគមន៍នៅទីនេះ ហ៊ុំព័ទ្ធដោយរឿងអកុសលជាច្រើន ដូចជា គ្រឿងញៀណ ស្រីពេស្យា បនល្បែង និង ការមើលងាយគ្នាជាដើម។ ដូច្នេះសន្តីម៉ារីម៉ាដាឡា ជាគំរូនៃជំនឿមួយរូប ដែលបានផ្លាស់ប្តូរចិត្តគំនិតពីបាបកម្មទាំងនោះ ហើយជឿលើព្រះយេស៊ូគ្រីស្ត។

លោកបូជាចារ្យឡាមុង កាព្រីអែល ឡង់ (ហ្គាប៊ី) បានមានប្រសាសន៍ថា សម្រាប់យើងជាគ្រីស្តបរិស័ទ យើងត្រូវយកគំរូតាមសន្តីម៉ារីម៉ាដាឡា ដោយអនុវត្ត និងប្រតិបត្តិជំនឿរបស់ខ្លួនជាគ្រីស្តបរិស័ទ នៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ ដោយបង្ហាញសេចក្តីស្រឡាញ់ ដូចសន្តីម៉ារី ម៉ាដាឡា ក្នុងការប្រកាសដំណឹងល្អដល់ឯទៀតៗ ឲ្យបានទទួលព្រះហឫទ័យមេត្តាករុណា និងប្រណីសន្តោសពីព្រះជាម្ចាស់នោះផង។

ព្រះវិហារ សន្តីម៉ារីម៉ាដាឡា នៃព្រះសហគមន៍ប៉ោយប៉ែត ត្រូវបានកសាងឡើងក្នុងឆ្នាំ១៩៩៥។ ជារៀងរាល់ឆ្នាំព្រះសហគមន៍នេះ បានរៀបចំកម្មវិធីថ្វាយអភិបូជា រំឭកដល់សន្តីម៉ារីម៉ាដាឡា ដែលជាឧបការីរបស់ខ្លួន។ នៅក្នុងរយៈពេល៥ឆ្នាំម្តង ព្រះសហគមន៍នេះ រៀបចំពិធីជាអធិកអធមម្តង ដោយមានការអញ្ជើញចូលរួម ពីសំណាក់បងប្អូនគ្រីស្តបរិស័ទ ពីបាត់ដំបងផងដែរ។

ក្រោយពេលបញ្ចប់កម្មវិធី ថ្វាយអភិបូជា បងប្អូនគ្រីស្តបរិស័ទទាំងអស់ បានចូលរួមពិសាអាហារសាមគ្គីជាមួយគ្នា៕

*ដោយឡុង សម្ផស្ស*

---

# ក្លិបកាតូលិកនាគរាជទទួលជ័យលាភីលេខខាងតេក្វាន់ដូ WTF

ជ័យលាភីលេខមួយ សម្រាប់ជំរើសជាតិឆ្នាំ២០១៥នេះ នៃការប្រកួតកម្មវិធីសហព័ន្ធកីឡា តេក្វាន់ដូពិភពលោក ហៅកាត់ថា ដាប់បាយូធីអេហ្វ (WTF) ត្រូវបានមកក្លិបកាតូលិកនាគរាជ មកពីខេត្តបាត់ដំបង ដែលការប្រកួតបានធ្វើឡើងកាលពីថ្ងៃទី១៩ ដល់២៥ កក្កដាកន្លងទៅនៅឯមជ្ឈមណ្ឌល ប៊ូយ៉ុងខ្មែរ (Booyoung Khmer) រាជធានីភ្នំពេញ។

លោកដួង វុទ្ធី ជាគ្រូបង្ហាត់តេក្វាន់ដូ និងជាស្ថាបនិក នៃក្លិបកាតូលិកនាគរាជបានមានប្រសាសន៍ថា ក្លិបកាតូលិកនាគរាជនេះបានជាប់ចំណាត់ថ្នាក់លេខ១ផ្ទួនគ្នា២ឆ្នាំ ដែលក្នុងឆ្នាំនេះយើងមានក្លិបចូលប្រកួតចំនួន៣៨។ វុទ្ធី "ឆ្នាំនេះ យើងបានទទួល មេដាយមាស៥ ក្នុងចំណោម៧វិញ្ញាសារ។ មេដាយប្រាក់៣ក្នុងចំណោម៥វិញ្ញាសារ និង មេដាយសំរិទ្ធ៤ក្នុងចំណោម៦វិញ្ញាសារ ដែលការប្រកួតនេះ មាន៣ប្រភេទ នៃវិញ្ញាសារ គឺមានវិញ្ញាសារសម្តែងវិញ្ញាសារមេគុណ និងវិញ្ញាសារប្រយុទ្ធ"។

លោកវុទ្ធីបន្ថែមថា ក្លិបរបស់លោក បានចូលប្រកួតកម្មវិធី សហព័ន្ធកីឡាតេក្វាន់ដូពិភពលោកហៅ កាត់ថា ដាប់បាយូធីអេហ្វ (WTF) ដោយឡែកក៏មានការប្រកួតសហព័ន្ធកីឡា តេក្វាន់ដូអន្តរជាតិហៅកាត់ថា អាយធីអេហ្វ (ITF) ផងដែរ ដែលការប្រកួតនេះត្រូវបានសហការរៀបចំឡើងដោយក្រសួងអប់រំ យុវជន និងកីឡា និងខេមរៈសហព័ន្ធតេក្វាន់ដូ។

ការប្រកួតទាំងលើផ្នែក ITF និង WTF មានក្លិបចូលរួមប្រកួតទាំងអស់ចំនួន ៥២ ដែលមានកីឡាករ និងការិនីសរុបចំនួន ៦០០នាក់ ក្នុងនោះមានផ្នែក WTF មានក្លិបចូលរួម ៣៨ ដែលមានអត្តពលិកសរុប ២២១ នាក់ ក្នុងនោះកីឡាការិនី មានចំនួន៨៦នាក់។ រីឯផ្នែក WTF មាន១៤ក្លិប ដែលមានអត្តពលិកសរុប ២៩៣ នាក់ ក្នុងនោះកីឡាការិនីសរុបមានចំនួន ៤០នាក់។

ភួន ថាវី អាយុ១៨ឆ្នាំ មកពីក្លិបកាតូលិកនាគរាជបានឲ្យដឹងថា សម្រាប់ប្រកួតថ្នាក់ជាតិនៅភ្នំពេញ ឆ្នាំនេះថាវីបានទទួលមេដាយមាស លើកដំបូងលើវិញ្ញាមេគុណ។ ថាវី បន្តថា នាងចង់បន្តហាត់តេក្វាន់ដូនេះបន្ថែមទៀត និងចង់ក្លាយជាកីឡាករជម្រើសជាតិ សម្រាប់ប្រទេស។ ថាវី "សម្រាប់ខ្ញុំ ខ្ញុំចង់ហាត់ព្រោះគេហាត់របៀបផ្សេង បច្ចេកទេសខុសពីយើង។ ខ្ញុំចង់ចូលជាជម្រើសជាតិ តែខ្ញុំខ្វះកម្ពស់។ ខ្ញុំចង់ទៅប្រកួតយកជំរើសជាតិ បើគេអនុញ្ញាត"។



*ក្រុមកីឡាតេក្វាន់ដូក្លឹបកាតូលិកនាគរាជ។ Photo supply*

បច្ចុប្បន្ននេះ ភួន ថាវី បានយកពេលវេលាខ្លះៗរបស់នាងដើម្បីបង្ហាត់យុវជនឯទៀតៗ អំពីកីឡាតេក្វាន់ដូនេះផងដែរ។ ថាវីឲ្យដឹងថា "សម្រាប់ខ្ញុំ ខ្ញុំស្រឡាញ់ពីដំបូង ជាកីឡាមួយជួយឲ្យសុខភាពខ្ញុំល្អ ខ្ញុំចង់ឲ្យលើកស្ទួយវិស័យនេះក្នុងខេត្តខ្ញុំ"។

ក្លិបកាតូលិកនាគរាជនេះ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៩។ បច្ចុប្បន្នក្លិបនេះ មានសិស្សប្រមាណ ៨០នាក់ ដែលសមាជិកហាត់មួយចំនួន ជាគ្រីស្តបរិស័ទ នៃក្រុមចម្រៀងក្នុងព្រះសហគមន៍ កាតូលិកបាត់ដំបង និងសិស្សសាលាមកពីខាងក្រៅ៕

*ដោយកញ្ញា*

# លោកអភិបាលធ្វើទស្សនកិច្ចនៅវិទ្យាល័យចម្រើនវិជ្ជា



*លោកគ្រូអ្នកគ្រូ និងគណៈគ្រប់គ្រងសាលាថតរូបអនុស្សាវរីយ៍។ រូបថតៈ សុធីរិទ្ធ*

លោកអភិបាល អូលីវីយេ ដ្មឹតអីស្លែរ ជាអភិបាលភូមិភាគភ្នំពេញ និងលោក អន់តូនីសាមី ស៊ូសែរាជ្យ ជាអភិបាលភូមិកំពង់ចាមបាន ធ្វើទស្សនកិច្ចសួរសុខទុក្ខបុគ្គលិក លោកគ្រូ អ្នកគ្រូ និង សិស្សានុសិស្ស នៃវិទ្យាល័យចម្រើនវិជ្ជា ស្ថិតនៅភូមិបារាយកើត ឃុំបារាយកើត ស្រុកព្រៃវែង ខេត្តព្រៃវែង កាលពីថ្ងៃទី ២២ កក្កដាកន្លងទៅ ដោយមានអ្នកចូលរួម ប្រមាណជាជាង១៥០នាក់។

លោកអភិបាល អន់តូនីសាមី ស៊ូសែរាជ្យ ជាអភិបាលភូមិភាគកំពង់ចាម បានមានប្រសាសន៍ក្នុងពិធីនោះថា វិទ្យាល័យចម្រើនវិជ្ជា ជាសាលាមួយដែលបានទទួលភាពជោគជ័យ នៅក្នុងវិស័យអប់រំនេះ ដោយសារការខិតខំរៀនរបស់សិស្សានុសិស្ស និងជាពិសេសមានការយកចិត្តទុកដាក់ ពីលោកគ្រូអ្នកគ្រូក្នុងការបង្រៀនផងដែរ។ លោកអភិបាល ក៏បានបញ្ជាក់ប្រាប់ផងដែរថា វិទ្យាល័យនេះ គឺយកគំរូ ពីវិទ្យាល័យចំណេះទូទៅ និងបណ្តុះបណ្តាលវិជ្ជាជីវៈសន្តហ្វ្រង់ស្វ័រ ដែលជាវិទ្យាល័យព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញនៅខេត្តតាកែវ។

លោកអភិបាលអូលីវីយេ ដ្មឹតអីស្លែរ បានមានប្រសាសន៍ក្នុងអង្គប្រជុំថា ៖ គាត់ពិតជា ជាសប្បាយចិត្តដែលបានមកទស្សនកិច្ចនៅទីនេះ។ លោកអភិបាល បានលើកទឹកចិត្តដល់សិស្សានុសិស្សទាំងអស់ឲ្យខិតខំតស៊ូ ដើម្បីទទួលបានជោគជ័យក្នុង ជីវិតជានិស្សិតក្នុងពេលឆាប់ៗខាងមុខនេះ។ លោកអភិបាល ក៏បានរំឭកដល់សិស្សានុសិស្សឲ្យខិតខំរៀនឲ្យចេះភាសាខ្មែរ ឲ្យបានច្បាស់លាស់ ហើយត្រូវមានជំនាញមួយពិតប្រាកដ រៀនភាសាអង់គ្លេសបន្ថែម ចេះបង្កើតទំនាក់ទំនងជាមួយគ្នានិងគ្នា និងត្រូវចេះបង្កើតគំនិតច្នៃប្រឌិតថ្មី។

ដើម្បីឲ្យបាន លទ្ធផលទាំងនេះ លោកអភិបាល បានលើកឡើងថា សិស្សានុសិស្សទាំងអស់ត្រូវការ "ការលើកទឹកចិត្ត និងចូលរួមជំរុញពីគ្រួសារ ការយកចិត្តដាក់របស់សង្គមលើប្រព័ន្ធអប់រំ ឲ្យមានភាពសុក្រិតល្អ ការចូលរួមពីលោកគ្រូ អ្នកគ្រូដោយយកចិត្តទុកដាក់ និងមានសមត្ថភាពក្នុងការបង្រៀនសិស្ស និងការយកចិត្តទុកដាក់ ដោយសិស្សខ្លួនឯងខិតខំប្រឹងប្រែង និងតស៊ូ"។

យុវនារីបឿន សុខហ៊ាន់ជាកូនសិស្សថ្នាក់ទី១២ម្នាក់ ក្នុងចំណោមកូនសិស្សថ្នាក់ទី១២ចំនួន៣៦នាក់ នៃវិទ្យាល័យចម្រើនវិជ្ជា បានមានចំណាប់អារម្មណ៍ថា៖ គាត់ពិតជាចូលចិត្តប្រព័ន្ធអប់រំរបស់វិទ្យាល័យចម្រើនវិជ្ជានេះណាស់គឺ វិទ្យាល័យនេះមានការអប់រំប្រកបដោយសុក្រឹតភាព យុត្តិធម៌ មានវិន័យតឹងរឹង និងជាពិសេសទៅទៀតនោះ គឺបង្រៀនពីរបៀបរស់នៅក្នុងសង្គម សេចក្តី ស្រលាញ់ ការជួយគ្នាទៅវិញទៅមកសុជីវធម៌ សីលធម៌ជាដើម។

វិទ្យាល័យចម្រើនវិជ្ជា ជាសាលាមួយរបស់ព្រះសហគមន៍កាតូលិក ដែលធ្វើការសហការជាមួយ រាជរដ្ឋាភិបាលកម្ពុជា ដើម្បីអប់រំយុវជន ពីកំរិតថ្នាក់ទី១០ដល់ទី១២ និងមានផ្តល់អាហារូបករណ៍មួយចំនួនដល់សិស្សកម្រិតឧត្តមសិក្សាផងដែរ។

តាមរបាយការណ៍សាលា បានឲ្យដឹងថា ក្នុងឆ្នាំ២០១៤កន្លងទៅ មានសិស្សចំនួន៣១នាក់ បានប្រលងជាប់មធ្យោមសិក្សាទុតិយភូមិ ក្នុងចំណោមសិស្សចំនួន៣៣នាក់ដែលក្នុងនោះមានស្រីចំនួន១៨នាក់។

ក្នុងដំណើរទស្សនកិច្ចនោះ លោកអភិបាលអូលីវីយេ បានផ្តល់អាហារូបករណ៍ចំនួន១០០%ចំនួន៥កន្លែងដល់សិស្សដែលនឹងប្រលងជាប់ក្នុងឆ្នាំសិក្សានេះ ដើម្បីរៀននៅថ្នាក់ឧត្តមសិក្សានៅវិទ្យាស្ថានសន្តប៉ូល ក្នុងខេត្តតាកែវ ៕

*ដោយ៉ារី និង ធីរិទ្ធ*

# សំណាក់ធម៌ពង្រឹងជំនឿដល់ចាស់ៗ

ព្រះសហគមន៍តំបន់កំពង់ចាម បានរៀបចំពិធីសំណាក់ធម៌ អ្នកស្វែងយល់ចាស់ៗប្រមាណជាជាង៤០នាក់ ដែលផ្តោតសំខាន់លើចិត្តសប្បុរស ក្នុងការជួយអ្នកដទៃ បានធ្វើឡើងកាលពីថ្ងៃ ទី១៧កក្កដាកន្លងទៅ នៅព្រះសហគមន៍កាតូលិកក្តុលលើ។

លោក ហ្វ្រង់ស័រ អេមេល្យដាល ជាបូជាចារ្យ ទទួលខុសត្រូវព្រះសហគមន៍កាតូលិកកំពង់ចាមក្រុង និងជាអ្នកណែនាំក្នុងកម្មវិធី សំណាក់ធម៌ចាស់ៗនេះ បានមានប្រសាសន៍ឲ្យដឹងថា៖ សំណាក់ធម៌ធ្វើឡើង ក្នុងគោលបំណងអប់រំអ្នកស្វែងយល់ចាស់ៗទាំងអស់ ឲ្យពួកគាត់ចេះចែករំលែកគ្នាស្រលាញ់គ្នា ដូចជាបងប្អូន ដោយមិនប្រកាន់វណ្ណៈ ព៌ណសម្បុរ និងពូជសាសន៍អ្វីឡើយ។ លោកបន្ថែមថា ជាពិសេសនោះគឺចង់ ឲ្យពួកគាត់យល់ថា យើងទាំងអស់គ្នា គឺប្រៀបដូចជនជាតិអ៊ីស្រាអែលម្នាក់ នៅក្នុងគម្ពីរដែលបានរងរបួសធ្ងន់ គឺយើងនេះហើយ ដែលរងបួសធ្ងន់ ដោយសារអំពើបាបរបស់យើង ហើយព្រះយេស៊ូ បានបន្ទាបខ្លួនព្រះអង្គផ្ទាល់ ដើម្បីស្រលាញ់យើង និងសង្គ្រោះយើងទាំងអស់គ្នារហូតមកដល់សព្វថ្ងៃនេះ។ គាត់បានបន្ថែមថា ដូចនេះ យើងជាគ្រីស្តបរិស័ទមានតួនាទី ស្រលាញ់គ្រប់មនុស្សទាំងអស់ដោយមិនប្រកាន់អ្វីឡើយ។

ក្នុងកម្មធីនេះ បានរៀបចំដូចជាការអប់រំអំពីធម៌មេត្តាករុណា ការចែកជាក្រុមតូចៗ ដើម្បីរិះគិត និងសំណួរផ្សេងៗតាមតម្រូវការ ហើយនឹងអធិដ្ឋានរួមគ្នា និង ច្រៀងអរព្រះគុណព្រះជាម្ចាស់។



*សំណាក់ធម៌ពង្រឹងជំនឿដល់ចាស់ៗនៅព្រះសហគមន៍តំបន់កំពង់ចាម។*

*រូបថតៈ Yet Minh*

អ្នកស្រីនួន ស៊ីណាតជាអ្នកកំពុងស្វែងយល់ម្នាក់ មកពីព្រះសហគមន៍កំពង់ចាមក្រុង បានមានប្រសាសន៍ឲ្យដឹងថា កម្មវិធីនេះបានជួយជាស់តឿនគាត់ច្រើនអំពីសេចក្តីស្រលាញ់ និងការអាណិតអាសូរ ហើយជាពិសេសទៀតនោះ គឺគាត់បានរៀនច្រើនអំពីសេចក្តីស្រលាញ់របស់ព្រះយេស៊ូ។

*ដោយ៉ារី*

# បងស្រីម៉ារីតាំង សុវឌ្ឍនៈថ្វាយពាក្យសច្ចានិរន្តរ៍




*បងស្រីតាំងសុវឌ្ឍនៈ (កណ្ដាល) នៅថ្ងៃថ្វាយពាក្យសច្ចានិរន្តរ៍។ ធីរិទ្ធ*

ម៉ារីតាំង សុវឌ្ឍនៈ ជាជាដូនជីជាតិខ្មែរដំបូង នៃក្រុមគ្រួសារបុត្រីព្រះនាងម៉ារីជាទីពឹងពំនាក់បានថ្វាយពាក្យសច្ចាប្រណិធានជានិរន្តរ៍នៅចំពោះមុខលោកអភិបាល លោកបូជាចារ្យ បងប្រុស បងស្រី និងគ្រីស្តបរិស័ទប្រមាណជាងមួយពាន់នាក់ ដែលមកពីព្រះសហគមន៍កាតូលិកបីភូមិភាគក្នុងប្រទេសកម្ពុជា។

បងស្រី ម៉ារី តាំងសុវឌ្ឍនៈវ័យ៣៥ឆ្នាំ មានស្រុកកំណើត នៅក្នុងខេត្តកំពង់ចាមបានប្រកាស នៅមុខគ្រីស្តបរិស័ទថាថ្វាយខ្លួន ដាក់ចិត្តបម្រើព្រះជាម្ចាស់ និងព្រះសហគមន៍ ដោយរស់នៅក្នុងភាពក្រីក្រ ដោយព្រហ្មចារីភាព និងដោយស្តាប់បង្គាប់ ក្នុងឋានៈជាអ្នកបួសអស់មួយជីវិត។ កម្មវិធីថ្វាយពាក្យសច្ចានិរន្តរ៍នេះ បានធ្វើឡើងកាលពីថ្ងៃទី ០៥ សីហា នៅមណ្ឌលសកម្មភាព ព្រះសហគមន៍កាតូលិកភ្នំពេញថ្មី។

និយាយលាយឡំ ជាមួយនឹងទឹកភ្នែកដោយសេចក្ដីរំភើបផងនោះ បងស្រីម៉ារី តាំង សុវឌ្ឍនៈ បាននិយាយថា បងស្រីបានត្រៀមខ្លួននិងរៀបចំខ្លួនយ៉ាងស្អាតបរិសុទ្ធ សម្រាប់ព្រះជាម្ចាស់ និងសម្រាប់យុវជនយុវនារី ដែលបងស្រីកំពុងនឹងបម្រើនាពេលខាងមុខ។ បងស្រីរូបនេះបានបន្តថា "អ្វីៗគ្រប់យ៉ាងដែលខ្ញុំត្រូវធ្វើនោះ គឺទាមទារយ៉ាងខ្លាំងនូវភក្តីភាពរបស់ខ្ញុំដូចព្រះយេស៊ូដែលមានភក្តីភាពចំពោះមនុស្សលោក។ ហើយចាប់ពីពេលនេះតទៅ គឺខ្ញុំត្រូវព្យាយាមឆ្លើយតបទៅនឹងភក្តីភាព របស់ព្រះគ្រីស្ត។ គឺជីវិតរបស់ខ្ញុំ នឹងរស់នៅសម្រាប់យុវជនក្រីក្រនិងអ្នកក្រីក្រយ៉ាងពិតប្រាកដ"។

បងស្រីតាំង សុវឌ្ឍនៈ បានធ្វើពិធីថ្វាយពាក្យសច្ចា លើកតំបូងក្នុងឆ្នាំ ២០០៩។

ក្នុងធម្មទេសនា លោកអភិបាល ដ្នីតអីស្លែ អូលីវីយេ ជាអភិបាលព្រះសហគមន៍ កាតូលិកភូមិភាគភ្នំពេញ មានប្រសាសន៍ថា ឆ្នាំនេះគឺជាឆ្នាំ បព្ជិតបព្វជិតា។ លោកអភិបាលបន្តថា យើងទាំងអស់គ្នាដឹងហើយថា នៅទីណាដែលមានបព្វជិតបព្វជិតា គឺមានអំណរសប្បាយ ដែលមកពីព្រះជាម្ចាស់សម្រាប់មនុស្សទាំងអស់។

លោកអភិបាលអូលីវីយេ បានសូមឲ្យបងស្រីបុត្រីព្រះនាងម៉ារី ជាទីពឹងពំនាក់មានវត្តមានឲ្យបានច្រើនកន្លែងជាពិសេស សម្រាប់កន្លែងដែលមានមនុស្សក្រីក្ររស់នៅ ដើម្បីអប់រំ និងផ្ដល់សេចក្ដីសង្ឃឹមដល់អ្នកទាំងនោះ។

ក្រុមគ្រួសារបងស្រី បុត្រីព្រះនាងម៉ារីជាទីពឹងពំនាក់ ជាក្រុមគ្រួសារបព្វជិតាកាតូលិក ដែលមានបេសកកម្មក្នុងការអប់រំកុមារ និងយុវជន ដែលមានដូចជាសាលាមត្តេយ្យ បឋមសិក្សាដល់ វិទ្យាល័យ និងវគ្គបណ្ដុះបណ្ដាលវិជ្ជាជីវៈសម្រាប់នារី។ ក្រុមគ្រួសារនេះ មានវត្តមាន នៅក្នុងប្រទេសកម្ពុជា ក្នុងឆ្នាំ ១៩៩២។

អ្នកស្រី ឈុន ប៊ុនណាត ជាម្ដាយរបស់បងស្រី តាំង សុវឌ្ឍនៈបានឲ្យដឹងថា អ្នកស្រីសូមឲ្យកូនស្រីដ៏ជាទីស្រលាញ់ធ្វើតាមអ្វីៗគ្រប់យ៉ាងដែលកូន បានប្រកាស និងសច្ចានៅមុខមហាជនទាំងអស់ ជាពិសេសកិច្ចការដែលកូន នឹងធ្វើក្នុងជីវិតជាអ្នកបួសនេះ។

អ្នកស្រី ក៏បានសំណូមពរ ដល់អាណាព្យាបាល និងឪពុកម្ដាយទាំងអស់សូមកុំបដិសេធចំពោះ បំណងប្រាថ្នារបស់កូនៗ របស់ខ្លួននៅពេលដែលគេមានចិត្ត ចង់ក្លាយជាអ្នកបួស ផ្ទុយទៅវិញសូមលើកទឹកចិត្តពួកគេនិងធ្វើតាមព្រះហឫទ័យព្រះជាម្ចាស់។

នៅជិតបញ្ចប់កម្មវិធីបងស្រីម៉ារី តាំង សុវឌ្ឍនៈបានប្រាប់ទៅដល់យុវជន យុវនារីទាំងអស់ ឲ្យហ៊ានធ្វើការឆ្លើយតបនឹងការត្រាស់ហៅជាអ្នកបួស។ បងស្រីសុវឌ្ឍនៈ "សូមទុកចិត្តទៅលើព្រះជាម្ចាស់ ព្រោះថា ព្រះជាម្ចាស់ត្រាស់ហៅអ្នកណាហើយ ទ្រង់ក៏មិនបានបោះបង់ចោលអ្នកនោះដែរ។ តែអ្វីដែលសំខាន់នោះគឺចិត្តសប្បុរសនៃការឆ្លើយតប"។

បច្ចុប្បន្នព្រះសហគមន៍កាតូលិកនៅកម្ពុជា មានគ្រីស្តបរិស័ទប្រមាណជាងពីរម៉ឺននាក់ ដែលក្នុងនោះមានអ្នកបួសជាតិខ្មែរប្រមាណជាង១០នាក់ប៉ុណ្ណោះ៕



*គ្រីស្តបរិស័ទ បងស្រីតាំងសុវឌ្ឍនៈ ទូលអង្វរសន្តបុគ្គល។ សុវណ្ណា*



*គ្រីស្តបរិស័ទ ជូនផ្កាបងស្រីតាំងសុវឌ្ឍនៈ។ សុវណ្ណា*

# ៨ចំណុចពី "LAUDATO SI" សម្រាប់កម្ពុជា



*លោកបូជាចារ្យខេនទីស កាព្រីអែល ឡុង (កាប៊ី)។ រូបថត: លី សុវណ្ណា*

កាលពីថ្ងៃទី១៨ មិថុនា សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានប្រកាសសារលិខិតជាលើកទីពីរជា" ឡាវដាតូ ស៊ី " ពាក្យនេះជាភាសា អ៊ីតាលីមានន័យថា "សូមកោតសសើរព្រះជាម្ចាស់" ជាឃ្លាមួយក្នុងពាក្យអធិដ្ឋានរបស់សន្តហ្វ្រង់ស៊ីស្កូ នៅអាស៊ីស៊ី។ សារលិខិតនេះ មិនមែនសម្រាប់តែព្រះសហគមន៍តូលិកប៉ុណ្ណោះទេ គឺ "ដល់មនុស្ស ដែលរស់នៅលើផែនដីទាំងមូលនេះ" ហើយនេះ ជាលើកទីមួយ ដែលសារលិខិតនេះ និយាយផ្តោតទៅលើបរិស្ថាន។ នៅខាងក្រោមនេះ មាន៨ចំនុចដែលសម្តេចប៉ាប បាននិយាយមកកាន់យើងនៅក្នុងស្រុកខ្មែរ។

១) រុក្ខជាតិ សត្វ និងអ្វីៗទាំអស់ដែលព្រះជាម្ចាស់បានបង្កើតមក វាមានតម្លៃឯករាជ្យរបស់វា។ ហើយវាមានតម្លៃព្រោះព្រះជាម្ចាស់បង្កើត ដោយសេចក្តីស្រលាញ់។ មិនមែនដើម្បី យើងប្រើប្រាស់ប៉ុណ្ណោះ តាមពិតទៅ យើងត្រូវតែគោរពនិងប្រើដោយយកចិត្តទុកដាក់។

២) យើងត្រូវតែយកពេលវេលាខ្លះគយគន់សោភ័ណ ដែលនៅជុំវិញខ្លួនយើង។ មានសោភ័ណភាព ៤ ដូចជាផ្ការីកដ៏ស្រស់ស្អាត សត្វល្អិតដ៏តូច ព្រះអាទិត្យលិចចូលសមុទ្រ និងអំពើល្អ។ ភាគច្រើន យើងរវល់ខ្លាំងពេក មិនអាចឈប់ និងមើលអំពីវត្តមានរបស់ព្រះជាម្ចាស់ ក្នុងសោភណភាពដែលនៅជុំវិញយើង។ ដើម្បីរៀនកោតសរសើរអ្វីដែលស្រស់ស្អាត យើងដាក់ព្រះជាម្ចាស់ក្នុងចិត្តយើង នោះយើងនឹងយល់តម្លៃនៃស្នាព្រះហស្ថរបស់ព្រះអង្គ។

៣) កត្តាមួយយើងគួរធ្វើ គឺឆ្ពោះទៅកាន់ ស្នាព្រះហស្ថព្រះជាម្ចាស់ដោយគ្មានការភ័យខ្លាច ឬការគាបសង្កត់ ប៉ុន្តែជាការដឹងគុណ។ យើងត្រូវយល់ថា ពិភពលោកនិងអ្វីៗទាំងអស់នេះ ជាអំណោយទានរបស់ព្រះជាម្ចាស់សម្រាប់យើងទាំងអស់គ្នា។ នាំឲ្យយើងនិយាយថា "សូមអរព្រះគុណ"។ អរគុណសម្រាប់ភ្លៀង ខ្យល់ដ៏បរិសុទ្ធ ម្ហូបដ៏មានជីវជាតិ ដែលបង្រៀនយើងឲ្យក្លាយជា បុត្រធីតាដែលចេះដាក់ខ្លួន ចំពោះព្រះភគ្គ្រព្រះបិតា។

៤) សូមពិនិត្យមើលវប្បធម៌ទំនើប និងកុំឆាប់ទទួលយកអ្វី ដែលអ្នកមើលឃើញនៅក្នុងសង្គមថាល្អ។ សង្គមបានផ្លាស់ប្តូរយ៉ាងលឿន ដែលយើងហៅថា "ភាពជឿនលឿន ឬការអភិវឌ្ឍ" វាមិនជួយផ្តល់ឲ្យមនុស្សនូវ កិត្តិយស សេចក្តីសុចរិត និងការលូតលាស់ឡើយ។ ជាទូទៅ សេដ្ឋកិច្ចកើនឡើងផ្តល់ឲ្យមានផលប៉ះពាល់ដល់បរិស្ថាន និង ប៉ះពាល់ដល់សហគមន៍។ ដូច្នេះយើងត្រូវចេះថ្លឹងថ្លែងថា អ្វីល្អទាំងនេះ គឺមកពីភាពមិនល្អជាច្រើន។

៥) សូមពិនិត្យមើលបែបផែននៃជីវិតរស់នៅរបស់ផ្ទាល់ខ្លួន។ តើរបៀបអ្នកធ្វើបានប៉ះពាល់ដល់បរិស្ថាន ឬអ្នកដទៃដែរទេ? ឧ៖ តើប៉ុន្មានដងអ្នកបានចោលសំរាម ប្រើដបជ័រទឹកសុទ្ធ ទុយោប៊ឺតទឹកប្រអប់ស្នោ? ជាញយដង យើងបានបោះវាចោលដោយមិនបានគិតថា យើងបង្កើតសំរាមនៅលើពិភពលោក ដែលធ្វើឲ្យប៉ះពាល់ដល់សត្វ ជីវៈចម្រុះ មនុស្សជំនាន់នេះ និងជំនាន់ក្រោយ។

៦) អ្វីដែលយើងបានបង្រៀននិងរៀនក្នុងគ្រួសាររបស់យើង គឺមានសារៈសំខាន់ណាស់សម្រាប់សង្គម។ ក្នុងគ្រួសារ យើងរៀននិយាយថា "សូមមេត្តា" ជំនួសពាក្យបញ្ជា។ ប្រើពាក្យ "អរគុណ" ចំពោះអ្វីដែលយើងបានទទួល។ និយាយថា "សុំទោស" ពេលយើងបានធ្វើខុស។ កាយវិកាសាមញ្ញនេះ ជួយបង្កើតវប្បធម៌នៃក្តីស្រឡាញ់ និង ការគោរពចំពោះមនុស្សនៅជុំវិញយើង និងក៏សម្រាប់ស្នាព្រះហស្តទាំងអស់ ក្នុងលោកនេះដែរ។

៧) មានកិច្ចការថ្លៃថ្នូរដែលបង្កា និងការពារបរិស្ថានបាន។ ពេលយើងថែរក្សាអ្វីដែលបានបង្កើតមក ដោយសកម្មភាពតូចតាចរាល់ថ្ងៃ ដូចជា ចៀសវាងប្រើប្រាស់ប្លាស្ទិច កាត់បន្ថយការប្រើប្រាស់ទឹក បង្ហាញដោយយកចិត្តទុក អ្វីដែលមានជីវិត និងបណ្តុះកូនឈើ ជាកត្តាមួយចូលរួមជួយដល់ពិភពលោក។ ទង្វើទាំងនេះ នឹងផ្តល់ផលដល់សង្គម និងជាពន្លឺបំភ្លឺ ដល់អ្នកដទៃឲ្យធ្វើតាម ដែលនាំឲ្យពិភពលោកផ្លាស់ប្តូរ។

៨) សូមពង្រីកការគិតយកចិត្តទុកដាក់របស់អ្នក។ អ្នកស្រឡាញ់ គ្រួសារ និងមិត្តរបស់អ្នក តែសូមបើកចិត្តស្រឡាញ់មនុស្សឯទៀតៗ និងអ្វីៗទាំងអស់ដែលបានបង្កើតមក។ ជាងនេះសូមអ្នកស្វែងយល់បន្ថែម អំពីព្រឹត្តិការណ៍សង្គម និងបរិស្ថាន។ ហើយសូមអាណិតអាសូរដល់បងប្អូនស្រី ដែលជាកម្មកររោងចក្រ បងប្រុសជាកសិករទុរគត ម្តាយជាទន្លេ និងឪពុកដែលជាព្រៃ។

សាររបស់សម្តេចប៉ាបនេះមានសារៈសំខាន់ណាស់ ដែលយើងគួរតែនាំគ្នាអនុវត្ត។ បរិស្ថានកំពុងរងការបំផ្លាញយ៉ាងដំណំ ហើយយើងទាំងអស់គ្នាគួររួមចំណែក ការពារសម្បត្តិធម្មជាតិនេះ។ បន្ទូលនេះណែនាំយើងឲ្យបានយល់អំពីបញ្ហាទាំងនេះនិងឲ្យយើងអាចធ្វើអ្វីមួយដើម្បីជួយអភិរក្ស សម្បត្តិធម្មជាតិ ក្នុងប្រទេសកម្ពុជាយើង៕

ដោយលោកបូជាចារ្យ កាប៊ី


## កម្មវិធីបោះជំរំនៃការត្រាសហៅ

" ក្រុមអេម៉ាណូអែល សាម៉ូអែល និងក្រុមអ្នកស្វែងយល់ពីការត្រាស់ហៅ "

**កម្មវត្ថុ :** គោរពអញ្ជើញចូលរួមកម្មវីធីបោះជំរំលើកទី៣ ឆ្នាំ២០១៥

" ព្រះជាម្ចាស់ស្រលាញ់ខ្ញុំ "!

សេចក្តីដូចបានជំរាបជូន ក្នុងកម្មវត្ថុខាងលើនេះ គណៈកម្មការត្រាស់ហៅអេម៉ាណូអែល និង សាម៉ូអែលទាំងបីភូមិភាគ មានសេចក្តីសោមនស្សរីករាយ សូមគោរពអញ្ជើញលោកអភិបាលលោកបូជាចារ្យ បងប្រុសបងស្រី និង ក្រុមបព្វជិតបព្វជិតា ចូលរួមកម្មវីធីបោះជំរំយុវជនយុវនារីលើកទី ៣ ប្រព្រឹត្តិទៅ នៅថ្ងៃទី ២០ ដល់ ២៣ ខែ សីហា ឆ្នាំ ២០១៥ ស្ថិតនៅព្រះវិហារសន្តមីការអែល ក្រុងព្រះសីហនុ។ អាស្រ័យដូចបានជំរាបជូនខាងលើ សូមលោកអភិបាល លោកបូជាចារ្យ បងប្រុសបងស្រី និង ក្រុមបព្វជិតបព្វជិតាអញ្ជើញប្អូនៗយុវជន យុវនារីមកចូលរួមកម្មវិធីបោះជំរំលើកទី៣នេះ ដោយអំណរ និងដើម្បីជួយឲ្យការត្រាស់ហៅរបស់ព្រះជាម្ចាស់ដល់ប្អូនៗយុវជនយុវនារីឲ្យបានច្រើនកុះករ ។

**ដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំនិងសូមព្រះជាម្ចាស់ប្រទានពរដល់បងប្អូនទាំងអស់នូវក្តីសុខសាន្ត !**

**ទំនាក់ទំនង ៖** **លោកបូជាចារ្យ អ៊ុន សុន** Tel : 012 79 58 00
**លោកបូជាចារ្យអាឌ្រីយ៉ាន បេនីតេសហ្គូស្តាវ៉ូ** Tel : 077 64 79 79

# បូជាចារ្យកាតូលិក៖ "បើចង់គោរពព្រះរបស់យើងយើងត្រូវគោរពមនុស្ស "




*តំណាងសាសនាថតរូបជុំគ្នាជាអនុស្សាវរីយ៍។ សហការី*

"បើចង់គោរពព្រះរបស់យើង យើងត្រូវគោរពមនុស្ស"។ នេះជាសំដីរបស់លោកបូជាចារ្យកាតូលិក នៅក្នុងសិក្ខាសាលា ស្តីពីសុខដុមនីយកម្ម ក្នុងវិស័យសាសនានៅកម្ពុជា ដែលរៀបដោយគណៈកម្មការទី៧នៃរដ្ឋសភា កាលពីថ្ងៃទី៣០ ខែកក្កដា ដែលមានតំណាងព្រះពុទ្ធសាសនា គ្រីស្តសាសនា និង ឥស្លាមសាសនា ប្រមាណជាង ២០០នាក់ ។

លោក បូជាចារ្យ ហ្វ្រង់ស្វ័រ ប៉ុងសូដ៍ ជាវាគ្មិនមួយរូប ក្នុងអង្គសិក្ខាសាលា តំណាងគ្រីស្តសាសនា បញ្ជាក់ថា តាមជំនឿរបស់ ព្រះសហគមន៍កាតូលិក យើងជឿថា មនុស្សជារូបតំណាងរបស់ព្រះជាម្ចាស់។ មនុស្សមានកិត្តិយសដ៏ខ្ពង់ខ្ពស់បំផុត។

លោកក៏បានលើកឡើងផងដែរ អំពីកិច្ចការនានា ដែលព្រះសហគមន៍កាតូលិក សម្រេចបាន ដោយយកចិត្តទុកដាក់ ខ្លាំងបំផុតចំពោះមនុស្ស ដែលនៅជាយសង្គម ដែលមានឋានៈតូចទាបក្រីក្រ ជនពិការ។ល។ លោកថា៖ "មនុស្ស សំខាន់ជាងគេ សង្គមសម្រាប់មនុស្ស មិនមែនមនុស្សសម្រាប់សង្គមនោះឡើយ"។ការអភិវឌ្ឍមានគោលដៅបម្រើមនុស្ស ឲ្យមានសេចក្តីសុខសាន្ត និងសុខដុមរមនា មិនមែនមនុស្សជាឧបករណ៍សម្រាប់ការអភិវឌ្ឍ។

អំពីសុខដុមនីយកម្ម ក្នុងវិស័យសាសនា និងសាសនា លោកថា ទោះបីយើងមានទស្សនៈខុសប្លែកគ្នា តែយើងអាចរួមគ្នាធ្វើសុខដុមនីយកម្មជាមួយគ្នាបាន។ ដោយលោកបានលើកនូវសកម្មភាពដែលគ្រីស្តបរិស័ទរួមជាមួយសាសនាព្រះពុទ្ធ និងឥស្លាមបានរួមគ្នាធ្វើចំពោះអ្នកក្រីក្រ។ លោកមានប្រសាសន៍ថា៖ "ក្រៅពីទ្រឹស្តី យើងអាចធ្វើការរួមគ្នាបាន។ យើងត្រូវរួមគ្នា ការពារលើកកម្ពស់កិត្តិយសរបស់មនុស្ស"។

នៅក្នុងសិក្ខាសាសនានេះ ព្រះសង្ឃ ឆាត សុធេត តំណាងព្រះពុទ្ធក៏បានលើកឡើងនូវចំណុចសំខាន់ៗ ដែលនាំឲ្យសុខដុមនីយកម្មក្នុង វិស័យសាសនា គឺការមិនបៀតបៀនគ្នា ការសាមគ្គីគ្នា និងការយល់ចិត្តគ្នា។

រីឯលោក មូសា អាលី តំណាងឥស្លាមសាសនា បានលើកចំណុចសំខាន់ដែលនាំមកនូវសុខដុមរមនា គឺការប្រាស្រ័យទាក់ទងល្អ និងសន្តិភាព។

លោក យ៉ែម បុញ្ញាឫទ្ធិ ប្រធានគណៈកម្មអប់រំ យុវជន កីឡា ធម្មការ កិច្ចការសាសនា វប្បធម៌ និងទេសចរណ៍ បានថ្លែងថា សិក្ខាសាលានេះមានគោលបំណង ពង្រឹងភាពសុខដុមនីយកម្មក្នុងវិស័យសាសនានៅកម្ពុជា និងស្វែងយល់ពីបញ្ហាប្រឈមមួយចំនួន ដើម្បីរកដំណោះស្រាយ ចូលរួមចំណែកអភិវឌ្ឍវិស័យសាសនាតាមក្រឹត្យក្រមនិងវិន័យ។

លោកក៏បានសម្តែង នូវការព្រួយបារម្ភផងដែរ ចំពោះការហូរចូលនូវទេសចរសាសនាអនាធិបតេយ្យ នាំមកនូវផលវិបាកជាច្រើន ដែលធ្វើឲ្យប៉ះពាល់ដល់ការគ្រប់គ្រង និងសណ្តាប់ធ្នាប់ក្នុងវិស័យសាសនា។ *សុវណ្ណា*

# សាលាដុនបូស្កូទឹកថ្លាចែកវិញ្ញាបនប័ត្រដល់សិស្សថ្នាក់ទី៦ និងទី៩

សិស្សានុសិស្ស នៃបឋមសិក្សា និងអនុវិទ្យាល័យ របស់សាលាដុនបូស្កូទឹកថ្លាចំនួនជាង ១០០នាក់ បានទទួលវិញ្ញាបនប័ត្របញ្ជាក់ការសិក្សា កាលថ្ងៃអាទិត្យ ទី១៩ ខែកក្កដា កន្លងទៅ ដែលមានការចូលរួម ពីតំណាងសាលា លោកគ្រូ អ្នកគ្រូ ព្រមទាំងមាតាបិតាសិស្សប្រមាណជាង២០០០នាក់។

បងស្រី ផាស៊ីវ៉ាន់ ធីបផាវ៉ាន នាយិការង នៃវិទ្យាល័យដុនបូស្កូ បានមានប្រសាសន៍ថា បងស្រីសូមស្វាគមន៍ និងសូមអរគុណ ចំពោះឪពុកម្តាយ អាណាព្យាបាលសិស្សទាំងអស់ ដែលបានសហការជាមួយសាលា និងបានចូលរួមនូវរាល់សកម្មភាពផ្សេងៗ ដែលសាលាមាន។ បងស្រីក៏មានប្រសាសន៍ជំរុញលើកទឹកចិត្ត ដល់ឪពុកម្តាយ និងអាណាព្យាបាលសិស្សទាំងអស់ ត្រូវបន្តខិតខំប្រឹងប្រែង ក្នុងការជួយអប់រំដល់កូនៗរបស់ខ្លួន ដើម្បីជួយឲ្យពួកគេក្លាយទៅជា មនុស្សល្អសម្រាប់សង្គមនាពេលខាងមុខ ។

បងស្រី បានបន្តថា៖ ឪពុកម្តាយអាណាព្យាបាលសិស្សត្រូវជួយតាមដាននូវរាល់សកម្មភាពរបស់កូនៗ នៅពេលដែលកូនៗ ឈប់សម្រាកវិស្សមកាលនេះ។ ឪពុកម្តាយ និងអាណាព្យាបាលសិស្សត្រូវជួយក្រំលឹកកូនឲ្យខិតខំរៀនសូត្របន្ថែមទៀត ឬរំលឹកមេរៀនចាស់ៗកន្លងមកនោះផង ដើម្បីតម្រង់ការអប់រំរបស់ពួកគេឆ្ពោះទៅអនាគត ។

ជាមួយគ្នានោះដែរ តំណាងសិស្សនៃវិទ្យាល័យដុនបូស្កូទឹកថ្លា បានលើកឡើងនូវការប្តេជ្ញាចិត្ត ដោយថ្លែងអំណរគុណចំពោះអាណាព្យាបាលនិងសាលាដែលបាន ជួយទំនុកបម្រុងសិស្សទាំងអស់ឲ្យបានសិក្សារៀនសូត្រ។ តំណាងសិស្សរូបនោះបន្តទៀតថា "កូនប្តេជ្ញាខិតខំប្រឹងប្រែងរៀនសូត្រ ដើម្បីក្លាយទៅជាកូនល្អ សិស្សល្អ និងជាពលរដ្ឋល្អសម្រាប់សង្គមជាតិទៅថ្ងៃអនាគត"។

ក្នុងពិធីចែកវិញ្ញាបនប័ត្រនេះផងដែរមានការដាក់បង្ហាញ ស្នាដៃហត្ថកម្មរបស់សិស្សតាមថ្នាក់នីមួយៗ ពីថ្នាក់មត្តេយ្យ ថ្នាក់បឋម អនុវិទ្យាល័យ និងវិទ្យាល័យ។

សាលាដុនបូស្កូ ជាសាលាអប់រំរបស់ព្រះសហគមន៍កាតូលិក ដែលគ្រប់គ្រងដោយក្រុមគ្រួសារបងស្រី សាលេស៊ាន ដុនបូស្កូ។ បច្ចុប្បន្ន ក្រុមបងស្រីមានសាលាមត្តេយ្យចំនួន៣កន្លែង បឋមសិក្សា២កន្លែង អនុវិទ្យាល័យ និងវិទ្យាល័យចំនួន១ និងមានបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់នារីចំនួន៣កន្លែង។

ឡុង សម្ផស្ស

# ព័ត៌មានកាតូលិកអន្តរជាតិ

## បុរីវាទីកង់ ៖ ដំណោះស្រាយអំពីភាពក្រីក្រគឺមិនឈរតែនៅលើបញ្ហាទីផ្សារតែមួយនោះទេ

បុរីវាទីកង់ បានរំលឹកជាថ្មី ទៅសហគមន៍អន្តរជាតិ ឲ្យបន្តយកចិត្តទុកដាក់នឹងភាពក្រីក្រ ហើយថាភាពក្រីក្រមិនគួរមានដំណោះស្រាយ ត្រឹមតែបញ្ហាទីផ្សារ។

លោកអគ្គអភិបាល បែណាទីតូ អូហ្សា តំណាងរបស់សន្តអសនៈ ប្រចាំនៅអង្គការសហប្រជាជាតិ នាបុរីញូវយ៉ក ថាសហគមន៍អន្តរជាតិ ដែលមាន ប្រទេសនានា គឺនៅតែប្រឈមមុខនឹងភាពក្រីក្រ និងបញ្ហាប្រឈមជាច្រើន ប្រសិនបើនាំគ្នាគិតត្រឹមតែ ដំណោះស្រាយអំពីបញ្ហាទីផ្សារនោះ។

តាមរយៈវិទ្យុវាទីកង់ លោកអគ្គអភិបាល បានមានប្រសាសន៍ថា បើចង់ដោះស្រាយបញ្ហានៃភាពក្រីក្រ គឺលុះត្រាតែរកឃើញ នូវដំណោះស្រាយមួយ ដែលឆ្លើយតបនៃបញ្ហានេះ មិនមែនដោះមួយជាប់ជំពាក់ នឹងបញ្ហាមួយទៀតនោះទេ ។

លោកក៏បាន មានប្រសាសន៍ថាដំណោះស្រាយនៃភាពក្រីក្រ និងភាពអត់ឃ្លានជាសាកល គឺមិនអាចដោះស្រាយត្រឹមតែបញ្ហាទីផ្សារតែមួយដាច់ខាត។

លោកបានបន្តថា ដើម្បីលុបបំបាត់ភាពក្រីក្រ និងគ្រោះអត់ឃ្លានបាន គឺមានតែការចែករំលែក នូវបច្ចេកវិទ្យា និងចំណេះដឹងវិទ្យាសាស្ត្រ តម្លៃនៃសីលធម៌ និងសាមគ្គីភាព ជាពិសេសគឺយុត្តិធម៌នៃសង្គម៕



លោកបូជាចារ្យហ្វ្រង់ស័រ ប៉ុងសូដ៍

**ថ្ងៃអាទិត្យទី ១៨ រដូវធម្មតា**
**(យហ៦,២៤-៣៥)**

ព្យាការីយេស៊ូស្ដីបន្ទោសគេ ព្រោះគេតែងតែរកប្រយោជន៍ផ្ទាល់ខ្លួន។ ថ្ងៃនេះ ព្រះអង្គក៏សួរយើងម្នាក់ៗថា តើហេតុអ្វីអ្នកប្ដូរជំនឿ ពីពុទ្ធសាសនាមកគ្រីស្ដសាសនាវិញ? តើអ្នកចង់បានអ្វី? ប្រហែលបងប្អូនខ្លះ ចង់រៀនសូត្រយ៉ាងស្រួល អ្នកខ្លះចង់បានការធ្វើ អ្នកខ្លះចង់ឲ្យព្រះសហគមន៍ជួយ។ល។

ព្រះយេស៊ូដាស់តឿនឲ្យយើងម្នាក់ៗចង់រួមរស់ ជាមួយព្រះបិតាជានិច្ច(លោកហៅការរួបរួមនេះថា "ជីវិតអស់កល្បជានិច្ច")។ នេះជាគោលបំណង តាមព្រះវិញ្ញាណរបស់គ្រីស្តបរិស័ទ ដូចពុទ្ធបរិស័ទមានបំណងចង់ចូលនិព្វានដូច្នេះដែរ។

ព្យាការីយេស៊ូរំឭកយើងថា មានកិច្ចការតែមួយគត់ដែលយើងត្រូវធ្វើ គឺត្រូវធ្វើជីវិតទាំងស្រុង ទៅលើលោកដែលបានបូជាជីវិតលើឈើឆ្កាង ហើយដែលណែនាំយើងឲ្យរួមរស់ជាមួយព្រះបិតា។ គោលដៅរបស់យើងនេះ គឺឲ្យរួមជាអង្គតែមួយនឹងព្រះបិតាជាបំណងតាមព្រះវិញ្ញាណ។ យើងត្រូវសុខចិត្តលះបង់ប្រយោជន៍ផ្ទាល់ខ្លួន ហើយសុខចិត្តបូជាជីវិតសម្រាប់អ្នកដទៃដូចព្យាការីយេស៊ូ។ គ្រប់វិនាទីយើងជាគ្រីស្តបរិស័ទ រួមរស់ជាមួយបងយេស៊ូដែលណែនាំយើងទៅកាន់ព្រះបិតា។

**ថ្ងៃអាទិត្យទី ១៩ ក្នុងរដូវធម្មតា**
**(យហ៦, ៤១-៥១)**

យើងត្រូវនឹកថា លោកយ៉ូហានសរសេរគម្ពីរយូរឆ្នាំក្រោយព្រះយេស៊ូទទួលព្រះជន្មថ្មីដ៏រុងរឿង។ នៅពេលនោះ ជនជាតិយូដាដែលធ្លាប់ស្គាល់ព្យាការីយេស៊ូយ៉ាងច្បាស់ ស្គាល់ទាំងឪពុកទាំងម្ដាយពិបាកទទួលថា ព្យាការីយេស៊ូនេះប្រសើរជាងលោកម៉ូសេ ដែលបង្កើតសាសនារបស់គេ។ គេក៏ពិបាកជឿថា លោកជាព្រះគ្រីស្ត ដែលណែនាំមនុស្សលោកឲ្យមានជីវិតរួមជាមួយព្រះបិតា ហើយរឹតតែពិបាកជឿថា លោកជាព្រះបុត្រារបស់ព្រះបិតាថែមទៀត។

លោកយ៉ូហានចង់ពន្យល់ថា ទោះបីព្យាការីយេស៊ូ រស់នៅដូចមនុស្សធម្មតាទាំងប៉ុន្មានក្ដីក៏លោកសម្ដែង អំពីកិត្តិយសដ៏ថ្លៃថ្នូរ នៃជីវិតធម្មតារបស់មនុស្សយើង និងរស់នៅដោយធ្វើជីវិតទាំងស្រុង លើព្រះបិតាជានិច្ច។ លោកពិតជាព្រះបន្ទូលដែលបង្ហាញអំពីកិត្តិយសនេះ និងទិសដៅនៃជីវិតមនុស្សយើង។

សព្វថ្ងៃអស់អ្នកដែលធ្វើជីវិតលើព្រះអង្គនឹងមានជីវិតរួមជាមួយព្រះបិតាមែន។ ប៉ុន្តែ ត្រូវនឹកចាំជានិច្ចថាជំនឿជាព្រះអំណោយទានរបស់ព្រះបិតា ដែលទាក់ទាញចិត្តយើង។

**បុណ្យព្រះជាម្ចាស់ លើកនាងម៉ារីឡើងស្ថានបរមសុខ(លក ១,៣៩-៥៦)**

គ្រីស្តបរិស័ទនាំគ្នាធ្វើពិធីលើកតម្កើងព្រះជាម្ចាស់ លើកនាងម៉ារីជាមាតាព្រះយេស៊ូទៅស្ថានខ្ពង់ខ្ពស់បំផុត តាមប្រពៃណីព្រះសហគមន៍។ តែគ្មានចែងសេចក្ដីនេះក្នុងគម្ពីរទេ។ បុណ្យនេះនាំឲ្យយើងរិះគិត អំពីឋានៈរបស់ព្រះយេស៊ូ ជាព្រះគ្រីស្តនិងជាព្រះអម្ចាស់តាំងពីមុនកំណើតពិភពលោក។ បុណ្យនេះ ក៏នាំឲ្យយើងរិះគិតអំពីឋានៈរបស់នាងម៉ារីដែរគឺនាងម៉ារីជាគ្រីស្តបរិស័ទគំរូ ព្រោះនាងធ្វើជីវិតលើព្រះជាម្ចាស់មុនគេបង្អស់។ នាងក៏ជាតំណាងរបស់ព្រះសហគមន៍ដែរ។

សូមបងប្អូនចាប់អារម្មណ៍អំពី ទារកលោតកញ្ឆេង ក្នុងផ្ទៃយាយអេលីសាបិតដូចព្រះបាទដាវីឌពីដើម លោតកញ្ឆេងនៅខាងមុខ ហិបរបស់ព្រះជាម្ចាស់ (២សម៦,១៦)។ អាចបញ្ជាក់ថា ទារកយេស៊ូក្នុងផ្ទៃនាងម៉ារី ពិតជាព្រះអម្ចាស់រីឯនាងម៉ារី ប្រៀបដូចជាហិបរបស់ព្រះអម្ចាស់វិញ។

នាងម៉ារី ថ្លែងបទលើកតម្កើងព្រះជាម្ចាស់។ តាមពិតបទនេះលោកលូកាស្រង់ពី ចម្រៀងរបស់គ្រីស្តបរិស័ទពីដើមមកដែលតែងតែ អរព្រះគុណព្រះជាម្ចាស់ ព្រោះព្រះអង្គ បានសង្គ្រោះប្រជារាស្ត្រតាមព្រះបន្ទូលសន្យា។ លោកនិពន្ធដូច្នេះដោយមានបំណងចង់បញ្ជាក់ថា នាងម៉ារីជា តំណាងព្រះសហគមន៍ដែលអរព្រះគុណព្រះជាម្ចាស់។

តើសព្វថ្ងៃនេះ ខ្ញុំទទួលស្គាល់សញ្ញាសម្គាល់ណាខ្លះដែលបញ្ជាក់ថា ព្រះបិតាសង្គ្រោះខ្ញុំ ក្នុងការរស់នៅរបស់ខ្ញុំ?

**ថ្ងៃអាទិត្យទី ២១ រដូវធម្មតា**
**(យហ ៦,៦០-៦៩)**

សូម្បីក្រុមសាវ័ក ដែលតាមព្យាការីយេស៊ូតាំងពីដើមរៀងមកក្ដី ក៏ពិបាកជឿថាលោកយេស៊ូ ដែលរស់នៅដូចមនុស្សឯទៀតៗបេះបិទ ហើយជាពិសេសដែលស្លាប់យ៉ាងសែនអាម៉ាស់ ដូចចោរម្នាក់ពិតជាព្រះអម្ចាស់និងជាព្រះគ្រីស្ត។

ព្រឹត្តិការណ៍ទាំងពីរនោះ ពិតជាឧបសគ្គមួយដ៏ធ្ងន់រាំងមិនឲ្យគេអាចធ្វើជីវិតលើព្រះយេស៊ូបាន។ ក៏ដូចបងប្អូនខ្មែរខ្លះសួរថា "ហេតុអ្វីយើងគោរពព្រះងាប់?"

យើងយកអ្នកដែលត្រូវគេសម្លាប់យ៉ាងសែនអាម៉ាស់ ដូចជាអ្នកទទួលបណ្ដាសានោះ ធ្វើជាព្រះអម្ចាស់ដែលប្រោសឲ្យយើងមានជីវិតរួមជាមួយព្រះបិតាជានិច្ច! ប្រសិនបើ យើងយល់ច្បាស់សេចក្ដីនេះយើង មុខជានឹងនិយាយដូចគ្រីស្តទូតប៉ូលដែលបានសរសេរថា ជំនឿរបស់យើងជាជំនឿលេលា (១ករ ១,១៨-២៥)។ យើងត្រូវចាំជានិច្ចថាជំនឿជាព្រះអំណោយទានរបស់ព្រះបិតា មិនមែនមកពីការខិតខំ ឬមកពីការរិះគិតរបស់មនុស្សទេ។ ហេតុនេះ ត្រូវអង្វរព្រះបិតាទាក់ទាញចិត្តគំនិតយើង ឲ្យធ្វើជីវិតលើព្រះយេស៊ូកាន់តែជិតស្និទ្ធឡើងៗ។

**ថ្ងៃអាទិត្យទី ២២ ក្នុងរដូវធម្មតា**
**(មក ៧,១-៨ និង ២១-២៣)**

ព្យាការីយេស៊ូ កំពុងជជែកវែកញែកជាមួយគ្រូអាចារ្យខាងគណៈផារីស៊ី។ "ផារីស៊ី" មានន័យថា "អ្នករស់នៅដាច់ពីគេ"។

ពួកគេមានបំណងចង់គាប់ព្រះហឫទ័យព្រះជាម្ចាស់យ៉ាងខ្លាំង ដោយចង់បាន "បរិសុទ្ធ" ដោយរស់នៅដាច់ពីអ្នកដទៃ ជាពិសេសដាច់ពីជនជាតិរ៉ូម៉ាំងដែលគេចាត់ទុកជាទមិឡឥតសាសនា។

ហេតុនេះ កាលគេត្រឡប់មកពីផ្សារ គេធ្លាប់ធ្វើពិធីបាចទឹកលើខ្លួន ហាក់ដូចជាពីធីលាងបាបម្យ៉ាង កុំឲ្យគេជាប់សៅហ្មងដោយគេបានប៉ះ "អ្នកបាប"។ ផ្ទុយពីព្យាការីយេស៊ូ ចូលចិត្តទាក់ទងជាមួយ "អ្នកបាប"។ លោកមិនធ្វើពិធីជម្រះខ្លួនតាមប្រពៃណីដូចគេទេ។

ដូច្នេះ ព្យាការីយេស៊ូរំឭកយើងថាអ្វីដែលគាប់ព្រះហឫទ័យព្រះបិតា គឺមកពីចិត្តគំនិតទៀងត្រង់បរិសុទ្ធ ការប្រែចិត្តគំនិត ហើយសុខចិត្តបូជាជីវិតសម្រាប់អ្នកដទៃ ដូចព្រះយេស៊ូ។ បើយើងមិនធ្វើតាមទេ ពិធីទាំងប៉ុន្មានសូម្បីតែអភិបូជាក៏មិនបានការទាល់តែសោះ៕

## កំណាព្យ ពិការកាយពិត តែចិត្តឥតពិការ

(បទពាក្យ ៧)



*និពន្ធដោយអ្នកស្រី ខុង ណារី,*
*មន្ត្រីគ្រប់គ្រងកម្មវិធីអប់រំ និង*
*សុខភាពនៃគម្រោងអភិវឌ្ឍន៍ជនបទ*
*អន្លង់ស្ដួល/JSC*

១- មានកាយជីវិតគិតវែង
អត់ទ្រាំក្នុងចិត្តតែសង្កត់
តស៊ូស្វះស្វែងដោយអំណត់
ផ្អែមល្ហឹងជូរចត់បទសោកា។

២- កុំកើតតូចចិត្តគិតអភ័ព្វ
ទោះបីងងឹតខ្វិនពិការ
រូបកាយពុំគាប់គ្មានវាសនា
ត្រូវតាំងចិត្តាឲ្យរឹងមាំ។

៣- សាងក្ដីសង្ឃឹមទៅថ្ងៃមុខ
គង់មានថ្ងៃថ្មីនឹងពាំនាំ
មិនត្រូវកើតទុក្ខប្រឹងស៊ូទ្រាំ
សោយកាយគ្រាំអស់ទុក្ខា។

៤- ថ្វីត្បិតរូបកាយពិការពិត
មិនឲ្យចុះចាញ់នឹងវាសនា
ចំណែកទឹកចិត្តឥតពិការ
ទោះបីយ៉ាងណាត្រូវតស៊ូ។

៥- រៀនដើម្បីចេះចំណេះឈាន
មានទេពកោសល្យល្អគំរូ
យើងបោះជំហានកុំគិតគូរ
គំពេងកើតប្ដូរជីវិតថ្មី។

៦- បង្កើតស្នាដៃថ្មីដៃខ្លួន
យើងអាចធ្វើបានមានទាស់អី
ដែលចេះចាំជូនគ្រប់អត្ថន័យ
ដូចមនុស្សប្រុសស្រីដទៃទៀត។

៧- ដែលកាយសម្បទាល្អគ្រប់គ្រាន់
រូបយើងពិការក៏មិនឃ្លាត
ចេះច្រើនឥតភាន់មិនរវាត
ជួយសង្គមជាតិបានមួយផ្នែក។

៨- ចេះច្រើនជួយច្រើនកើនសង្គម
ចេញពីទឹកចិត្តល្អអនេក
ទោះតិចតួចជំរួមចំណែក
មិនរស់ពឹងផ្អែកអ្នកដទៃ

៩- មានទេពកោសល្យផ្ដល់អត្ត
ជាជនពិការខ្វិនជើងដៃ
ប្រយោជន៍ជឿជាក់ពិតមានន័យ
មានចិត្តគក្ដីជួយសង្គម។

# វិទ្យាស្ថានសន្តប៉ូល



## ថ្នាក់បរិញ្ញាបត្រ
### វិស្វកម្មកម្មវិធី (Software Engineering)

- **មហាវិទ្យាល័យព័ត៌មានវិទ្យា** Faculty of Information Technology
  - វិស្វកម្មកម្មវិធី ( Software Engineering )
  - ទូរគមនាគមន៍ និងបណ្តាញ ( Telecommunication and Network )
- **ដេប៉ាតឺម៉ង់អក្សរសាស្ត្រអង់គ្លេស** Department of English Literature
  - អប់រំភាសាអង់គ្លេស ( Teaching English as Foreign Language)
  - ភាសាអង់គ្លេសសម្រាប់ទំនាក់ទំនង ( English for Communication)
- **ដេប៉ាតឺម៉ង់គ្រប់គ្រងទេសចរណ៍** Department of Tourism Management
- **ដេប៉ាតឺម៉ង់កសិកម្មសាស្ត្រ** Department of Agronomy
- **ដេប៉ាតឺម៉ង់សង្គមកិច្ច** Department of Social Work

## ថ្នាក់បរិញ្ញាបត្ររងជំនាញបច្ចេកទេស

- **អភិវឌ្ឍន៍កម្មវិធីកុំព្យូទ័រ** Software Development
- **គ្រប់គ្រងប្រព័ន្ធ និងបណ្តាញកុំព្យូទ័រ** System and Network Administration
- **បង្រៀនភាសាអង់គ្លេសជាភាសាទីពីរ** Teaching English As Second Language
- **សណ្ឋាគារ និងបដិសណ្ឋារកិច្ច** Hotel and Hospitality
- **ផលិតកម្មដំណាំឈើហូបផ្លែ និងបន្លែ** Fruit and Vegetable Crop Production
- **ជំនាញកែច្នៃអាហារ** Food Processing
- **ប្រព័ន្ធកសិកម្មចម្រុះ** Integrated Farming System
- **ពេទ្យសត្វ** Veterinary
- **ថែទាំកុមារ** Child care

## លក្ខខណ្ឌចូលរៀន

**សម្គាល់ ៖** រៀនបន្ថែម២ឆ្នាំនឹងទទួលបានសញ្ញាបត្របរិញ្ញាបត្រ

១. បេក្ខជនត្រូវមានសញ្ញាបត្រទុតិយភូមិ (ជាប់ថ្នាក់ទី១២)
ឬសញ្ញាបត្រដែលមានតម្លៃស្មើសម្រាប់ចូលរៀនថ្នាក់បរិញ្ញាបត្រ

២. បេក្ខជនធ្លាក់ថ្នាក់ទី១២ អាចចូលរៀនថ្នាក់បរិញ្ញាបត្ររងជំនាញបច្ចេកទេស

**ចាប់ផ្តើមលក់ពាក្យ និងទទួលពាក្យ**

* ចូលរៀនវគ្គបំប៉ន ខែកញ្ញា ឆ្នាំ២០១៥
* ចូលរៀនឆមាសទី១ ខែវិច្ឆកា ឆ្នាំ២០១៥

អាសយដ្ឋាន៖ ភូមិអង្គគីរ ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ

Tel: 032 639 0002 / 032 639 0003 Email: spi.takeo@gmail.com | Web: www.spi.edu.kh

## សេចក្តីជូនដំណឹង

" លោហិតមរណសាក្សី គឺគ្រាប់ពូជរបស់ព្រះសហគមន៍ " (Apologeticus, Chapter 50:Tertullian)។ បងប្អូនជាទីស្រឡាញ់ ព្រះសហគមន៍កាតូលិកកម្ពុជារីកចម្រើនដោយសារឈាមមរណសាក្សី។ ខ្ញុំលោកបូជាចារ្យ រឿង ផ៉ត្រសិរី អ្នករៀបចំសំណុំរឿង (Postulator) បានប្រមូលព័ត៌មានមួយចំនួនហើយ ប៉ុន្តែសូមបងប្អូនជួយផ្តល់ព័ត៌មានបន្ថែមអំពីអ្នកបម្រើរបស់ព្រះជាម្ចាស់ថែមទៀតដូចជា រូបថត អត្ថបទឬសៀវភៅដែលគាត់សរសេរ វត្ថុអនុស្សាវរីយរបស់គាត់ខ្លះ ។ល។ សូមផ្តល់ឈ្មោះអ្នកដែលអាចផ្តល់សក្ខីភាពបានជូនមកឲ្យខ្ញុំតាមរយៈអាសយដ្ឋានខាងក្រោម

**Tel : 077 800 211 / 096 34 22 144** ប្រអប់សំបុត្រលេខ ១២៣ រាជធានីភ្នំពេញ Email: martyrscambodia@gmail.com